ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jun-2015, 08:30
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ១៣:៣១នាទី**

**សវនាការលើកទី២៩៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង) *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក កែវ លឿ (2-TCW-932) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កែវ លឿ** (2-TCW-932)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ទំព័រ ៣
សួរដោយលោក វីល្មៀម ស្មីត ផ្ដើមពី.........................................................................ទំព័រ ៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[១៣:៣១:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះចាប់ផ្តើមធ្វើសវនាការ ស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-932។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះ កោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅរសៀលនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-932 ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។

សាក្សីបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីព្រឹកមិញថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ នេះ។ ហើយសាក្សី មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[១៣:៣៣:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី សែកុលវុឌ្ឍី។

ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើបញ្ហាពីរ។ ទី១ គឺជូនដំណឹងជម្រាបជូនដល់ភាគីនៃរឿងក្តី

ទាំងអស់ជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិ អវត្តមានដោយមូលហេតុបញ្ហាសុខភាព ហើយគាត់មិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការនេះបាន ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាង ភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមានរហូតដល់ពេលលោកចៅក្រម យូរ ឧត្តរា មានវត្តមាន និងអាចមានលទ្ធភាពបំពេញការងារនៅក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះ ផ្អែកលើបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[១៣:៣៤:៣៣]

បញ្ហាមួយទៀតអង្គជំនុំជម្រះសម្រេច លើសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិ និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ និងកាន់តែឈឺខ្លាំងនៅពេលអង្គុយយូរ។ ហើយបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយរសៀលថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទនួន ជា អាច

ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលថ្ងៃនេះ។

ជាបន្តបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[១៣:៣៧:១៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី! តើលោកឈ្មោះអី?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទឈ្មោះ កែវ លឿ។

**ស៖** អរគុណលោក កែវ លឿ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** ខ្ញុំបាទកើតនៅថ្ងៃ១៥ ខែ៩ ឆ្នាំ១៩៥១។

**ស៖** អរគុណលោក កែវ លឿ។ ហើយលោកមានទីកន្លែងកំណើតនៅទីណា?

**ឆ៖** ខ្ញុំបាទកើតនៅភូមិរនាម ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោកនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងស្នាក់អាស្រ័យបច្ចុប្បន្ន ខ្ញុំបាទនៅភូមិដាំផល ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបរអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** បាទ ធ្វើស្រែចម្ការធម្មតា។

**ស៖** បាទ អរគុណ។ ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ កែវ លាង ម្តាយឈ្មោះ សៃ ស៊ន។

**ស៖** បាទ អរគុណ។ ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយាខ្ញុំបាទ ឈ្មោះ សុខ សារ៉េត។ ខ្ញុំបាទមានកូនប្រាំបីនាក់។

[១៣:៣៩:៣៤]

**សៈ** បាទ អរគុណលោក កែវ លឿ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរទេ?

**ឆៈ** បាទ ពិតមែន។

**សៈ** បាទ អរគុណ។ ហើយរបាយការណ៍ដដែលបានបញ្ជាក់ថា លោកបានស្បថរួចហើយមុននឹងចូលមកកាក់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ តើពិតមែនដែរទេ?

**ឆៈ** បាទ ខ្ញុំបាទបានស្បថពិតមែន។

**សៈ** បាទ អរគុណលោក កែវ លឿ។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោក ក្នុងនាមលោកជាសាក្សី អំពីសិទ្ធិ លោក កែវ លឿ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកអះអាងដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច លោក កែវ លឿ ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតបរបស់លោក ឬក៏ការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។

[១៣:៤១:២៨]

ក្នុងឋានៈជាសាក្សី នៅ -- លោកត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក កែវ លឿ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើបានប៉ុន្មានដងហើយធ្វើនៅទីកន្លែងណា? ពេលណាលោកចាំទេ?

**ឆៈ** ខ្ញុំបាទ បានសម្ភាសពិតប្រាកដមែន ក៏ប៉ុន្តែខ្ញុំបាទបានចាំថ្ងៃខែទេទានប្រុស។

**សៈ** បាទ មិនអីទេ លោក កែវ លឿ។ ហើយមុននឹងចូលមកដល់ចំពោះមុខអង្គជំនុំជម្រះនៅ

ពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអានទូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតកាលពីលើកមុនដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំបាទបានអានពីរដង តែពុំបានចាំបានច្បាស់ទេទានប្រុស។

[១៣:៤២:៤៩]

**ស៖** តាមសមត្ថភាពដែលលោកអាចដឹងនិងចាំបាន ថាតើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំ ដែលលោកបានអានពីរដងអម្បាញ់មិញនេះ។ តើពិតជាត្រឹមត្រូវ ឬក៏វាស៊ីចង្វាក់ស្របគ្នានឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី កែវ លឿ មុនភាគីដទៃទៀតនៃរឿងក្តី ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលបីវគ្គ នៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

**លោក វីណ្ស៊ៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី។

[១៣:៤៤:០៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** ហើយជម្រាបសួរលោកសាក្សី។ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា សួរសំណួរមួយចំនួនអំពីបទពិសោធន៍របស់លោកនៅក្នុងអំឡុងរបបខ្មែរក្រហម។ ប៉ុន្តែខ្ញុំឱ្យលោកផ្តោតពិសេសទៅលើបទពិសោធន៍របស់លោកនៅព្រលានយន្តហោះកំពង់ឆ្នាំង ដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ ខ្ញុំក៏នឹងពិភាក្សាជាមួយលោកនូវអ្វីដែលកើតឡើងទៅលើសមាជិកកងទ័ពនៃ

កងពល៣១០ ដែលលោកជាកងទ័ពនៅក្នុងកងពលនេះដែរ។ ប៉ុន្តែមុននឹងចាប់ផ្ដើមសួរសំណួរទាំងនេះ ខ្ញុំសួរសំណួរខ្លីៗខ្លះទៅកាន់រូបលោកពាក់ព័ន្ធនឹងប្រវត្តិរូបលោក ហើយនិងបទពិសោធន៍នៅក្នុងអំឡុងពេលខ្មែរក្រហម។ សំណួរទាំងអស់នេះគឺថាចេញមកពី -- មានទាំងអស់ប្រហែលជា៥០ទំព័រ លោកប្រធាន គឺឯកសារ E3/568 មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំសួរសំណួរខ្លីៗទេ ទាក់ទងទៅនឹងឯកសារនេះ ហើយបើសិនជាត្រូវការលេខ ERN ខ្ញុំនឹងផ្ដល់ជូនមុននឹងចូលប្រធានបទ ទៅសួរអំពីព្រលានយន្តហោះកំពង់ឆ្នាំង។

**ស៖** នៅថ្ងៃទី១៨ ខែកញ្ញា មួយពាន់ប្រាំ-- ថា១៩៧០ គឺលោកមានអាយុ១៨ឆ្នាំ ហើយលោកក៏បានចូលបម្រើនៅជាមួយនឹងចលនាបដិវត្តន៍របស់ប៉ុល ពត មែនទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

[១៣:៤៦:០២]

**ស៖** ហើយលោកក៏បានជម្រាបទៅអ្នកសម្ភាសន៍ពីមជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅក្នុងឆ្នាំ១៩៧១ លោកកើតជំងឺគ្រុនចាញ់ លោកក៏បានទៅផ្ទះវិញមួយរយៈពេលខ្លីដើម្បីឲ្យជាសះស្បើយ មុននឹងត្រឡប់មកសមរភូមិមុខវិញជាមួយនឹងកងពល៣១០ វរសេនាៗតូច២១០។ តើៗចំណុចនេះត្រឹមត្រូវដែរទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយ។ នៅឆ្នាំ៧១ ខ្ញុំបាទមានជំងឺគ្រុនចាញ់ ហើយវិលត្រឡប់មកផ្ទះវិញពិតមែន។

**ស៖** សូមអរគុណ។ ក្រោយពីលោកជាសះស្បើយហើយ លោកទៅចូលរួមជាមួយកងពល៣១០ វរសេនាតូច៣១៧ វិញទេ?

**ឆ៖** បាទ ខ្ញុំបាទបានទៅចូលក្នុងអង្គភាពវិញពិតប្រាកដ។

**ស៖** ហើយតើត្រឹមត្រូវទេ ថានៅក្នុងឆ្នាំ១៩៧៤ លោកចូលរួមវាយប្រយុទ្ធជាមួយទាហានលន់ នល់ ហើយនៅពេលមួយនោះ នៅក្នុងឆ្នាំ១៩៧៤ហ្នឹង នៅថ្ងៃទី ០៥ ខែធ្នូ លោកត្រូវបានដំឡើងបុណ្យស័ក្តិទៅជាអនុកងវរសេនាតូចនៅពេលនៅរលួស ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ពិតប្រាកដ។

**ស៖** ហើយតើពិតដែរទេ ដែលថានៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលលោកចូលវាយប្រយុទ្ធរំដោះទីក្រុងភ្នំពេញ លោកត្រូវរបួសនៅនឹងជើង ហើយលោកបាក់ជើង ហើយលោកត្រូវទៅសម្រាកនៅមន្ទីរ

ពេទ្យ។ តើអ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** នៅថ្ងៃ០១ ខែ០១ ខ្ញុំបាទបានចូលសមរភូមិត្រូវរបួសបាក់ជើងឆ្វេងពិតប្រាកដមែន ហើយបានទៅសម្រាកនៅមន្ទីរពេទ្យ។

[១៣:៤៩:០១]

**ស៖** សូមអរគុណ។ តើហ្នឹងគឺជាថ្ងៃទី០១ ខែមករា ១៩៧៥ អ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ ថ្ងៃ០១ ខែ០១ ឆ្នាំ១៩៧៥ ពិតប្រាកដ។

**ស៖** សូមអរគុណ។ ហើយក្រោយមកលោកត្រូវបញ្ជូនទៅកង ក-៤ ដើម្បីសម្រាកឲ្យជាសះស្បើយនៅជិតមន្ទីរពេទ្យកាល់ម៉ែត ដោយសារតែរោគរងរបួសនេះឯង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន។

**ស៖** ហើយតើលោកសម្រាកនៅ ក-៤ ហ្នឹងអស់រយៈពេលប៉ុន្មានទម្រាំនឹងជាសះស្បើយ?

**ឆ៖** ខ្ញុំពុំបានចាំអំពីខែថ្ងៃទេ ទានប្រុស។

**ស៖** លោកចាំទេ លោកសម្រាកតែរយៈពេលពីរបីសប្តាហ៍ ឬក៏ពីរបីខែ ឬក៏អស់រយៈពេលដល់ឆ្នាំឯណោះ? លោកអាចស្មានៗ លោកអាចគិតប៉ាន់ប្រមាណមើល សម្រាកនៅ ក-៤ អស់រយៈពេលប្រហែលប៉ុនណាដែរ?

**ឆ៖** បើតាមខ្ញុំបាទស្មានប្រហែលជាបីខែ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ អង្គភាពក-៤ហ្នឹង ជាអង្គភាពអ្វីដែរ? ហើយគេប្រើប្រាស់សម្រាប់ធ្វើអ្វី? ហើយសមាជិករបស់ក-៤ ហ្នឹងជាសមាជិកបែបណាដែរ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គចៅក្រម ក-៤ គឺមន្ទីរពិការ មានសមាជិកប្រហែលជា៦០០។

**ស៖** នៅពេលដែលលោកឆ្លើយថា ជាអង្គភាពជនពិការនេះ គឺសំដៅតែកងទ័ពដែលពិការដោយសារតែត្រូវរបួសអ៊ីចឹង ហើយមកសម្រាកព្យាបាល ឬក៏លោកនិយាយសំដៅទៅលើប្រជាជនដែលគាត់ពិការ មានពិការភាពក្នុងខ្លួនជាទូទៅតែម្តង ពីកំណើតអ៊ីចឹងតែម្តង?

**ឆ៖** សូមជម្រាបជូនអង្គចៅក្រម អង្គភាពក-៤ គឺសម្រាប់ទ័ពដែលពិការ ហើយគេប្រមូលទៅដាក់មួយកន្លែង។ ឈ្មោះអង្គភាព ក-៤។

**ស៖** ប្រហែលជាប្រធានបទនេះ ខ្ញុំសួរតែមួយសំណួរទៀតទេ។ តើលោកកត់សម្គាល់ឃើញនៅអង្គភាពក-៤ ហ្នឹងភាគ -- គឺថាជនពិការហ្នឹងពិការរបៀបណាដែរ? ជាទូទៅហ្នឹងពិការទៅលើអ្វីដែរ?

ឆ៖ នៅក្នុងអង្គភាព ក-៤ ដែលប្រមូលពីអង្គភាពនានាមក ខ្លះបាក់ដៃ ខ្លះបាក់ជើង ខ្លះក៏ខ្វាក់ភ្នែក អ្នកពិការទូទៅទាំងអស់។ គឺនៅក្នុងអង្គភាពនោះគឺ សុទ្ធតែអ្នកពិការខ្លះក៏បាក់ដៃបាក់ជើង ហើយពិការភ្នែកនិងស្នូតជាដើម ដែលត្រូវគ្រាប់។

[១៣:៥៣:៣០]

ស៖ ហើយរបួសរបស់លោកវិញ គឺលោកបាក់ជើង។ តើរបួសនេះជារបួសពិការអស់មួយជីវិតតែម្តង ឬក៏ពិការមួយរបបខ្មែរក្រហមតែម្តង? ឬមួយក៏ថាវាជាសះស្បើយឡើងវិញ ដូចជាមិនពិការយូរអឺចឹង ឬមួយជីវិតអឺចឹងទេ?

ឆ៖ ខ្ញុំបាទត្រូវពិការអស់មួយជីវិត គ្រាន់តែបច្ចុប្បន្នអាចដើរបាន តែធ្វើការងារពុំបាន។ អត់បានលីសែងទេ បានតែដើរ។

ស៖ សូមអរគុណ។ តើត្រឹមត្រូវទេដែលថា ក្នុងឆ្នាំ១៩៧៦ លោកនៅតែជាសមាជិកអង្គភាព ក-៤ដដែល ហើយលោកក្លាយទៅជាកងអនុសេនាធំនៅក្នុងអង្គភាពហ្នឹងតែម្តង ត្រឹមត្រូវទេ?

ឆ៖ បាទ ពិតប្រាកដមែន។

ស៖ ហើយនៅពេលណាមួយនោះក្នុងឆ្នាំ១៩៧៦ លោកបានឆ្លើយថា លោកត្រូវបានគេចាប់ខ្លួន ហើយក៏បញ្ជូនខ្លួនទៅកប់ស្រូវបណ្តោះអាសន្ន ដោយសារតែលោកហ្នឹងជាកម្មាភិបាលមកពីភូមិភាគឧត្តរ។ តើត្រឹមត្រូវដែរទេ?

ឆ៖ នៅពេលដែលគេចាប់កងពល កងវរសេនាធំ វរៈមួយចំនួន ខ្ញុំត្រូវគេបញ្ជូនទៅនៅកប់ស្រូវ ដើម្បីធ្វើការលត់ដំ ពិតប្រាកដមែន។

[១៣:៥៥:៤៩]

ស៖ ហើយលោកដឹងទេថា ហេតុអ្វីបានជាសមាជិកទាំងនេះមកពីភូមិភាគឧត្តរត្រូវបានគេចាប់ខ្លួន?

ឆ៖ រឿងគេចាប់អ្នកធំៗ ខ្ញុំបាទពុំបានដឹងទេទានប្រុស។

ស៖ ហើយតើលោកបានប្រាប់ទៅអ្នកសម្ភាសន៍ថា នៅក្នុងឆ្នាំ១៩៧៧ មានការបោសសម្អាតក្នុងកងពល៣១០ គឺគេបោសតែថ្នាក់ដឹកនាំកងពល៣១០។ ហើយដោយសារតែការបោសសម្អាតថ្នាក់ដឹងនាំកងពល៣១០ហ្នឹង លោកក៏ក្លាយទៅជាអនុកងវរសេនាធំនៅក្នុងអង្គភាពក-៤។ ត្រឹមត្រូវដែរឬទេ?

ឆ៖ នៅពេលគេចាប់កម្មាភិបាលបោសសម្អាត គេឲ្យខ្ញុំបាទទទួលជាវរសេនាតូចបណ្តោះ

អាសន្នទានប្រុស នៅក្នុងអង្គភាពក-៤ នេះ។

[១៣:៥៧:០០]

**ស៖** ហើយដោយសារតែការចាប់ខ្លួននេះ លោកបានឆ្លើយថាលោកត្រូវបានបញ្ជូនទៅឃ្លាំញកប់ស្រូវ ជាបណ្ដោះអាសន្នសិន។ តើមានន័យថាម៉េចហ្នឹង "បញ្ជូនទៅឃ្លាំញកប់ស្រូវជាបណ្ដោះអាសន្ន" ហ្នឹង?

**ឆ៖** គេបញ្ជូនខ្ញុំបាទឲ្យទៅនៅកប់ស្រូវ ទៅនៅអង្គភាពមួយទៀត អង្គភាពដែលគេចម្រាញ់លត់ដំ គឺឈ្មោះអង្គភាព៣១៧។

**ស៖** ហើយថាហេតុអ្វីបានជាគេបញ្ជូនលោកទៅឲ្យលត់ដំ? លោកថាមានការចាប់ខ្លួនកម្មាភិបាលភូមិភាគឧត្តរ ហើយដោយសារតែការចាប់ខ្លួនកម្មាភិបាលភូមិភាគឧត្តរ លោកក៏ត្រូវបញ្ជូនទៅទីនោះបណ្ដោះអាសន្ន គឺថាលត់ដំបណ្ដោះអាសន្ន។ តើលោកមានទំនាក់ទំនងអ្វីរវាងការបញ្ជូនទៅលត់ដំបណ្ដោះអាសន្ន និងការចាប់ខ្លួននេះ?

**ឆ៖** ការណ៍ដែលគេបញ្ជូនទៅនៅលត់ដំ គេថាយើងនៅអង្គភាពខ្មាំងនៅពេលនោះ។ គេឲ្យទៅនៅលត់ដំនៅកន្លែងនោះ គឺគេចោទថាយើងជាខ្មាំង។

**ស៖** តើលោកជាខ្មាំងមែនឬ? តើលោកជាខ្មាំងរបស់ខ្មែរក្រហម ជាខ្មាំងរបស់បក្សមែនឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទ អត់ដឹងអីទាំងអស់នៅពេលនោះ ស្រាប់តែគេហៅទៅលត់ដំ។ គេថាយើងជាកម្មា-ភិបាលចាស់។

**ស៖** តើលោកជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទពុំបានជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ ទានប្រុស។

[១៤:០០:៣៥]

**ស៖** ហើយលោកក៏បានប្រាប់ទៅអ្នកស៊ើបអង្កេតដែរថានៅក្នុងឆ្នាំ១៩៧៧ ក្រោយពីការចាប់ខ្លួនមេដឹកនាំនៅកងពល៣១០ ភូមិភាគឧត្តរ ដោយតែជាប់ទាក់ទៅនឹង សេ.អ៊ី.អា មេដឹកនាំរបស់ភូមិភាគៗបស្ចិមហ្នឹង ក៏បញ្ជូនទៅគ្រប់គ្រងនៅទីនោះ ហើយលោកក៏ត្រូវគេបញ្ជូនមកព្រលានយន្តហោះកំពង់ឆ្នាំង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំបាទនៅលត់ដំនៅឃ្លាំញបាន៥ខែ ហើយគេបញ្ជូនទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។

**សៈ** សូមអរគុណ។ លោកបានឆ្លើយថានៅក្នុងឆ្នាំ១៩៧៦ លោកត្រូវបានគេបញ្ជូនទៅឃ្លាំងកប់ស្រូវ ហើយលោកក៏បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា នៅថ្ងៃទី១៥ ខែមករា ១៩៧៨ លោកត្រូវបានគេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង។ សំណួរដែលខ្ញុំសួរទៅលោកនេះ តើលោកបានឆ្លើយថាលោកត្រូវបានគេបញ្ជូនទៅកំពង់ឆ្នាំងនៅថ្ងៃទី១៥ មករា ១៩៧៨ មែនឬក៏អត់ទេ? លោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហេតុអ្វីបានជាគេបញ្ជូនលោកទៅកំពង់ឆ្នាំងនៅថ្ងៃទី១៥ ខែមករា ១៩៧៨?

[១៤:០២:៤៣]

**ឆៈ** នៅថ្ងៃ១៥ ខែមករា ៧៨ គេបញ្ជូនឲ្យទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។

**សៈ** តើហេតុអ្វីបាន -- ធ្វើម៉េចបានជាលោកចាំកាលបរិច្ឆេទនេះច្បាស់លាស់ម្ល៉េះ?

**ឆៈ** ការចាំនេះ ដោយបានអានបណ្តើរៗ ហើយនៅចាំក្នុងជីវិតរបស់ខ្ញុំ។

**សៈ** សូមអរគុណ។ លោកបានឆ្លើយថា លោកត្រូវបានគេបញ្ជូនទៅឃ្លាំង កប់ស្រូវដើម្បីឲ្យលត់ដំ។ តើការបញ្ជូនទៅឲ្យលត់ដំ ជាៗការដាក់ទណ្ឌកម្មដែរ ជាការដាក់វិន័យទណ្ឌកម្មដែរ ឬក៏អត់ទេ?

**ឆៈ** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ សូមបានជ្រាប។ នៅកន្លែងនោះគឺលត់ដំ ម៉ោងបីក្រោកប្រជុំជួរ ហើយចេញទៅធ្វើការ រហូតដល់ម៉ោងមួយបានឲ្យទៅហូបបាយថ្ងៃត្រង់។ ម៉ោងដប់យប់ ហូបបាយ។ នៅពេលនោះ គឺពេលដែលយើងខ្ញុំទុក្ខលំបាកខ្លាំង។

**សៈ** ដូច្នេះ ខ្ញុំនិយាយថា នៅពេលដែលបញ្ជូនលោកឲ្យទៅលត់ដំហ្នឹង គឺគេឲ្យលោកធ្វើការធ្ងន់ធ្ងរជាងអ្នកដទៃទៀត។ តើអ៊ីចឹងឬក៏អត់ទេ?

**ឆៈ** នៅក្នុងវរៈ៣១៧ វរៈលត់ដំនេះ គឺធ្វើការទាំងអស់គ្នា លត់ដំ។

[១៤:០៥:២១]

**សៈ** ហើយថាហ្នឹងមុនពេលគេបញ្ជូនលោកទៅព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏អត់ទេ? គឺថាតើកងវរៈរបស់លោកទាំងមូលហ្នឹងត្រូវគេបញ្ជូនទៅលត់ដំទាំងអស់ឬអត់ទេ មុនពេលលោកទៅដល់កំពង់ឆ្នាំង?

**ឆៈ** គេពុំបានបញ្ជូនទៅពីអង្គភាពទេ គឺគេដកពីនេះខ្លះពីនោះខ្លះ យកទៅចម្រុះគ្នា ទៅធ្វើការនៅកំពង់ឆ្នាំង។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់ តើលោកបាននិយាយថានៅក្នុងឆ្នាំ១៩៧៧ លោកក្លាយជាអនុប្រធាន -- អនុកងវរសេនាធំនៅក្នុងអង្គភាពក-៤ ដោយសារតែគេបោសសម្អាតមេដឹកនាំទៅ។ អ៊ីចឹងលោកក៏បានឡើងជាៗអនុកងវរសេនាធំ អ៊ីចឹងមែនទេ?

[១៤:០៦:៣១]

**ឆ៖** នៅពេលដែលគេបោសសម្អាតកម្មាភិបាលអស់ គេបានចាត់តាំងខ្ញុំបាទ បន្តុបឲ្យជាអនុវរសេនាតូច ក-៤។ បាទ មិនមែនវរសេនាធំទេទានប្រុស។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា លោកបានទៅដល់កំពង់ឆ្នាំងនៅថ្ងៃទី១៥ ខែមករា ១៩៧៨។ តើលោកនៅព្រលានយន្តហោះកំពង់ឆ្នាំងរហូតដល់វៀតណាមចូលមកដល់ភ្នំពេញ ឬក៏អត់ទេ? តើលោកនៅទីនោះពេញឆ្នាំ១៩៧៨រហូតដល់វៀតណាមចូលមកភ្នំពេញ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា ខ្ញុំបាទនៅកំពង់ឆ្នាំងពេញ១ឆ្នាំរហូតដល់ថ្ងៃ៧ មករា ខ្ញុំបាទរត់គេចចេញពីផ្ទះបាទ។

**ស៖** សូមអរគុណ។ នៅក្នុងឆ្នាំនុ៎ង តើគេមានឲ្យលោកចូលរៀនសូត្រអីនៅភ្នំពេញឲ្យរៀនសូត្រនៅភ្នំពេញ ហើយក្រោយឲ្យត្រឡប់ទៅកំពង់ឆ្នាំងវិញនៅឆ្នាំដដែលហ្នឹង ឬក៏អត់ទេ?

**ឆ៖** នៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង គេបានចម្រាញ់រកអ្នកចេះដឹងឲ្យមករៀននៅភ្នំពេញ ដើម្បីទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងវិញទានប្រុស។

[១៤:០៨:៤៩]

**ស៖** តើត្រឹមត្រូវទេដែលថា ការរៀនសូត្រហ្នឹងគឺមានរយៈពេលប្រហែលជា៣ខែ?

**ឆ៖** បាទ រៀនសូត្រប្រហែលជា ៣ខែពិតប្រាកដមែន។

**ស៖** តើ ៣ខែហ្នឹងលោករៀនអំពីអ្វី?

**ឆ៖** ក្នុងរយៈពេល៣ខែ ខ្ញុំបាទរៀនខាងបច្ចេកទេសថ្លឹងដី។

**ស៖** ហើយលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា លោកនៅព្រលានយន្តហោះកំពង់ឆ្នាំងប្រហែលជា ២ខែក្រោយថ្ងៃ១៥ មករា ១៩៧៨ នៅតែ២ខែទេ ហើយក្រោយមកលោកត្រឡប់មកភ្នំពេញវិញ មករៀនសូត្ររយៈពេល៣ខែ ហើយក៏ត្រឡប់ទៅព្រលានយន្តហោះកំពង់ឆ្នាំងវិញ គឺថាពេញមួយអំឡុងពេលឆ្នាំ១៩៧៨ រហូតលោករត់គេចយួននៅថ្ងៃ០៧ មករា ១៩៧៩។ តើនេះជាការរៀបរាប់ត្រឹមត្រូវរបស់លោកជូនអ្នកស៊ើបអង្កេតអ៊ីចឹងមែន ឬក៏អត់ទេ?

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា ការណ៍នេះជាការពិតដែលខ្ញុំបាទបានឆ្លើយនេះ វាពិតប្រាកដ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរអំពីចំនួនមនុស្សធ្វើការនៅព្រលានយន្តហោះ។ ស្ថានភាព -- លក្ខខណ្ឌការងារដែលលោកធ្វើនៅទីនោះ ជាមួយអ្នកដទៃទៀត ហើយថាតើ -- និងការចាប់ខ្លួនដែលលោកបាននិយាយ និងការរៀនសូត្រលត់ដំនៅឃ្លាំញកប់ស្រូវ។ ខ្ញុំសួរសំណួរបន្តិចទៀតនេះ ពាក់ព័ន្ធទៅនឹងចំណុចទាំងនេះ។ អ៊ីចឹងសំណួរដំបូងនេះ គឺថាហេតុអ្វីបានជាលោកត្រូវបានគេជ្រើសរើសឲ្យទៅរៀនសូត្រ នៅពេលដែលគេបញ្ជូនលោកដំបូង គឺថាបញ្ជូនទៅឲ្យរៀនសូត្រលត់ដំ ហើយម៉េចបានគេជ្រើសរើសមកឲ្យរៀនសូត្រនៅភ្នំពេញវិញ?

[១៤:១១:៣៨]

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំ ខ្ញុំបាទនៅកប់ស្រូវលត់ដំរហូតដល់ធ្វើការងារក្នុងនាមខ្ញុំបាទជាអ្នកពិការជើង រែកដី រហូតដល់ដួលសន្លប់ពីរបីដង ហើយគេក៏បញ្ជូនទៅកំពង់ឆ្នាំង។ ទៅកំពង់ឆ្នាំងនេះធ្វើការមិនបានធ្ងន់ដល់នៅឃ្លាំញកប់ស្រូវទេ ទានប្រុស គឺស្រាលជាងនោះ គឺមានការដកស្មៅ ជីកឫស តាមឫស។ នេះសូមអង្គជំនុំមេត្តាជ្រាប។

**ស៖** ហើយអ្នកណាមកប្រាប់លោកថា ឲ្យលោកទៅរៀនសូត្រនៅភ្នំពេញ? តើលោកទទួលព័ត៌មានថាគេឲ្យទៅរៀនសូត្រនៅភ្នំពេញហ្នឹងពីអ្នកណា?

**ធ៖** នៅពេលនោះ ខ្ញុំបាទបានជួបនឹង បងហាន ដែលធ្លាប់បានរួមចំណែកវ៉ៃក្នុងសមរភូមិទាំងអស់គ្នាបានស្គាល់គាត់ ហើយគាត់ក៏បានសុំឲ្យខ្ញុំទៅរៀនជាមួយនឹងគេ។

**ស៖** សូមអរគុណ។ ក្នុងវគ្គរៀនសូត្រហ្នឹង គឺថាលោកយកចិត្តទុកដាក់រៀនសូត្រណាស់ គឺថាលោករៀនបានជាប់ចំណាត់ថ្នាក់លេខ២ ក្នុងមួយវគ្គហ្នឹង។ ត្រឹមត្រូវដែរឬក៏អត់ទេ?

**ធ៖** បាទ ពិតប្រាកដមែន។

**ស៖** នេះជាសំណួរចុងក្រោយទៅលើប្រធានបទមួយនេះ។ លោកបានឆ្លើយថាលោកជាអនុកងវរសេនាតូចមួយរយៈនៅអង្គភាពក-៤។ តើលោកនៅតែកាន់តួនាទីនេះដដែលទេ នៅពេលដែលលោកទៅកំពង់ឆ្នាំង? តើគេនៅតែចាត់ទុកលោកថាលោកជាអនុបញ្ជាការកងវរសេនាតូចដដែលទេ ពេលទៅកំពង់ឆ្នាំង?

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំជម្រះ ទៅកំពង់ឆ្នាំ គឺនៅនាមជាយុទ្ធជនទាំងអស់គ្នាបាទ។ អត់មានតួនាទីដូចមុនទៀតទេ។

[១៤:១៤:៥៣]

**ស៖** តើគេអនុញ្ញាតឲ្យលោកកាន់កាំភ្លើងទេ ពេលនោះ ពេលនៅកំពង់ឆ្នាំង?

**ឆ៖** ទៅនៅកំពង់ឆ្នាំង គ្មានអ្នកណាកាន់កាំភ្លើងទេទាន សូមមេត្តាជ្រាប។

**ស៖** លោកដឹងទេ ហេតុអ្វីបានជាគេមិនឲ្យកងទ័ពកាន់កាំភ្លើង?

**ឆ៖** ខ្ញុំបាទពុំបានដឹងអំពីបទបញ្ជាផ្ទៃក្នុងរបស់គេទេ គេអត់ឲ្យមានកាំភ្លើងក៏អត់ទៅ។ នៅពេលនោះ មានតែសង្រែក ដងរែក និងបង្គីប៉ុណ្ណោះ។

**ស៖** ខ្ញុំសូមអានឲ្យលោកស្ដាប់នូវអ្វីដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺឯកសារ E3/467, ERN អង់គ្លេស 00205--, ខ្មែរ 00170620, បារាំង 00205078។ នេះគឺអ្វីដែលលោកឆ្លើយទៅនឹងសំណួរនេះ នៅពេលដែលគេបញ្ជូនលោកទៅរៀន -- ទៅបណ្ដោះអាសន្ននៅកំពង់ឆ្នាំង។ តើគេឲ្យលោកធ្វើអ្វី? លោកឆ្លើយថា៖ "អង្គភាពរបស់ខ្ញុំមានសមាជិកនៅសល់ប្រហែលជា ៤០០នាក់ នៅពេលដែលគេបញ្ជូនយើងជាបណ្ដោះអាសន្នទៅកំពង់ឆ្នាំង។ មានអង្គភាពផ្សេងៗទៀតដែរ ដូចជាកងពល៤៥០។ ដំបូងគេឲ្យខ្ញុំដកស្មៅនៅព្រលានយន្តហោះ ហើយធ្វើការពីម៉ោង៤ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ និងពីម៉ោង១១:៣០ រហូតដល់ម៉ោង១១យប់។ នៅក្នុងពេលប្រជុំនោះគេនិយាយថា យើងត្រូវតែលត់ដំខ្លួន ពីព្រោះមេៗរបស់ពួកយើង គឺថាគឺជាពួកអ្នកក្បត់ ហើយបើយើងម្នាក់ៗមិនលត់ដំទេ គេនឹងចាប់អ្នកឯងដែរ។ តាឡៃ មកពីភូមិភាគពាយ័ព្យជាអ្នកកាន់កាប់ព្រលានយន្តហោះ។ នៅកន្លែងហ្នឹង ខ្ញុំបានឃើញមនុស្សស្លាប់ដោយសារធ្វើការហួសកម្លាំង និងអត់បាយ។ មានឡានមកចាប់មនុស្សរាល់ៗយប់ ដោយមួយពេលៗចាប់មនុស្សប្រហែលជា២០នាក់។ ពេលប្រជុំគេបានហៅឈ្មោះឲ្យចេញពីអង្គប្រជុំ ហើយចាប់ខ្លួនតែម្ដង។ នៅអង្គភាពខ្ញុំនៅសល់តែ១៤នាក់ទេ ដែលនៅរស់"។ តើរឿងរ៉ាវនេះពិតមែន ឬក៏អត់ទេ នូវអ្វីដែលបានកើតឡើងនៅព្រលានយន្តហោះកំពង់ឆ្នាំង នៅឆ្នាំដែលលោកបានទៅទីនុំង បន្ទាប់ពីលោកបានរៀនសូត្រហើយ?

[១៤:១៨:២៥]

**ឆ៖** នៅពេលនោះ ជារឿងពិត។ ហ្នឹងសូមអង្គជំនុំជម្រះមេត្តាជ្រាប។

**ស៖** លោកនិយាយថា អង្គភាពរបស់លោកធ្វើការនៅព្រលានយន្តហោះដំបូងមាន៤០០នាក់ សមាជិក៤០០នាក់ ហើយក្រោយមកថា "ក្នុងអង្គភាពខ្ញុំនេះ ក្នុង៤០០នាក់ហ្នឹង គឺថានៅសល់តែ១៤នាក់ទេនៅរស់រានមានជីវិត"។ តើសមាជិក៣៨៦នាក់ ដែលទៅពីអង្គភាពក-៤ នុំង គឺៗថាស្លាប់អស់ហើយ

នៅពេលដែលលោកនៅកំពង់ឆ្នាំង ឬក៏លោកគ្រាន់តែនិយាយមកដល់សព្វថ្ងៃនេះទេ ថាមកដល់សព្វថ្ងៃហ្នឹងគឺលោកឃើញតែ ១៤នាក់ ឬក៏លោកនិយាយថាពេលហ្នឹងសល់តែ១៤នាក់?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួររបស់តំណាងព្រះរាជអាជ្ញារងអន្តរជាតិ។ តាមសក្ខីកម្មរបស់សាក្សីកន្លងមក គាត់បញ្ជាក់ថានៅក្នុងអង្គភាពរបស់គាត់ហ្នឹងមិនមែនយកអង្គភាពក-៤ ទាំងអស់ទៅកំពង់ឆ្នាំងទេ គឺមានដកពីកន្លែងផ្សេងៗមកទៀត។ ដូច្នេះ ខ្ញុំ -- បើសិនជាសាក្សីឆ្លើយបញ្ជាក់ថា ៤០០នាក់នេះជាៗសមាជិកចេញពីអង្គភាពក-៤នោះ អាហ្នឹងសូមឲ្យបញ្ជាក់ឲ្យច្បាស់សាជាថ្មី។ ក៏ប៉ុន្តែអ្វីដែលខ្ញុំឮកន្លងមកគឺ មិនដូច្នោះទេបាទ។ សូមអរគុណ។

[១៤:២០:១៧]

**សួរដោយលោក វីល្លៀម ស្មីត៖**

ខ្ញុំយល់ថាជាការបញ្ជាក់ច្បាស់ពីខាងមេធាវីការពារក្តី។

**ស៖** លោកសាក្សី នៅពេលលោកទៅព្រលានយន្តហោះ តើសមាជិកទាំង៤០០នាក់ នៃអង្គភាពរបស់លោកហ្នឹង ទៅទាំងអស់គ្នាទីហ្នឹង ឬក៏ខ្លះមិនទៅទេ ទៅខ្លះ នៅខ្លះ?

**លោក កែវ លឿ៖**

**ឆ៖** នៅពេលដែលធ្វើដំណើរទៅកំពង់ឆ្នាំង គេពុំបានទៅទាំងអស់ទេ គឺដកបញ្ចូលគ្នាពីនេះខ្លះ ពីនោះខ្លះ បញ្ចូលគ្នាទៅកំពង់ឆ្នាំង។

**ស៖** សូមអរគុណ។ តើកងអង្គភាពរបស់លោកហ្នឹងទៅប៉ុន្មាននាក់ទៅកំពង់ឆ្នាំង?

**ឆ៖** ខ្ញុំបាទ ពុំបានចាំអស់ទេទានប្រុស។

**ស៖** លោកបានឆ្លើយថា "ក្នុងកងរបស់ខ្ញុំនោះ គឺថានៅតែ១៤នាក់ទេ នៅរស់"។ ក្នុងចំណោមប្រជាជនដែល -- ក្នុងចំណោមសមាជិកអង្គភាពក-៤ ដែលទៅជាមួយលោកនោះ មានអ្នកណាបាត់ខ្លួន ឬក៏ត្រូវបានចាប់ខ្លួនដែរឬក៏អត់ទេនៅក្នុងឆ្នាំដែលលោកទៅនៅកំពង់ឆ្នាំងហ្នឹង?

[១៤:២២:១៤]

**ផ៖** កាលដែលខ្ញុំបាទនៅកំពង់ឆ្នាំង គឺមានការចាប់ជាបន្តបន្ទាប់ដែលគេចោទថាខ្សែខ្មាំង នេះគឺពិតប្រាកដ។

**ស៖** នៅពេលលោកនិយាយថាមានការចាប់ខ្លួនបន្តបន្ទាប់។ តើមានការចាប់ខ្លួននៅក្នុងកងរបស់លោកទេ ឬក៏មានតែការចាប់ខ្លួនក្នុងកងដទៃទៀតដែលធ្វើការនៅឯការដ្ឋានព្រលានយន្តហោះហ្នឹង?

**ផ៖** មិនមែនចាប់តែកងខ្ញុំទេ គឺគ្រប់កងទាំងអស់ដែលទៅធ្វើការលត់ដំនៅកន្លែងនោះ។

**ស៖** តើគេអនុញ្ញាតឲ្យលោកដើរចេញពីកន្លែងធ្វើការងារហ្នឹងទេ បើលោកចង់ដើរ?

**ផ៖** គេមិនបានអនុញ្ញាតឲ្យយើងដើររហេតរហូតទេទានប្រុស គឺនៅមួយកន្លែង។

**ស៖** តើគេអនុញ្ញាតឲ្យលោកបដិសេធមិនធ្វើការទេ? តើលោកអាចប្រកែកមិនធ្វើការទេ បានទេ?

**ផ៖** នៅពេលនោះ ការងារមិនអាចប្រកែកបាន ទោះបីមានជំងឺក្តី គឺត្រូវតែទៅ បើមិនទៅគេចោទថាខ្មាំង ម្ល៉ោះហើយចេះតែស៊ូទ្រាំទៅធ្វើការ។

**ស៖** តើការងារនៅទីហ្នឹងលោកបានទទួលកម្រៃទេ គេមានឲ្យសោហ៊ុយថ្លៃការងារឲ្យលោកទេ?

**ផ៖** នៅការងារកន្លែងនោះ គ្មានកម្រៃអីទាំងអស់ សូម្បីតែហូបក៏មិនបានគ្រប់គ្រាន់ផង។

**ស៖** លោកមានពេលឈប់សម្រាកទេ មានថ្ងៃឈប់សម្រាក ឧទាហរណ៍មួយអាទិត្យឈប់មួយថ្ងៃ មួយខែឈប់មួយថ្ងៃ ឬក៏មួយរយៈពេលណាឈប់មួយថ្ងៃ។ មានពេលឈប់សម្រាកដែរទេ?

[១៤:២៥:០៥]

**ផ៖** ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា គ្មានថ្ងៃអាទិត្យថ្ងៃព្រហស្បតិ៍ទេ។ ធ្វើការមួយខែ ពេញមួយខែ។

**ស៖** ប្រសិនណាជាលោកអស់កម្លាំងខ្លាំងពេក ហើយលោកចង់សម្រាន្ត លោកមិនទៅធ្វើការ។ តើអាចធ្វើអ៊ីចឹងបានទេ?

**ផ៖** មិនអាចធ្វើទៅបានទេ ដូចខ្ញុំបាទបានជម្រាបហើយថាយើងមិនធ្វើការ គេថាយើងគ្រុនញាក់គ្រុនញ៉ីវ គ្រុនត្រាក់ទ័រ គ្រុនខ្យល់ដិល គេចោទថា "ខ្មាំង"។

**ស៖** និយាយអំពីសមាជិកនៃអង្គភាពរបស់លោកដែលមកពីក-៤។ លោកឆ្លើយថា សមាជិកហ្នឹងគឺថាជាជនពិការដោយត្រង់ផ្នែកណាមួយនៃរាងកាយ។ តើសមាជិកនៃកងរបស់លោកនេះ អនុញ្ញាតមិនឲ្យទៅប្រយុទ្ធបានទេ ដោយសារស្ថានភាពសុខភាពមិនល្អ ឬក៏ពិការយ៉ាងដូច្នេះ?

**ផ៖** ខ្ញុំបានស្តាប់អត់ទាន់យល់ សូមបញ្ជាក់ម្តងទៀតទានប្រុស។

**ស៖** តើមនុស្សនៅក្នុងកងរបស់លោក តើគេជាសះស្បើយអាចទៅប្រយុទ្ធទេ? ហើយមានទៅប្រយុទ្ធវិញទេ?

**ឆ៖** ជនពិការទាំងអស់ គេមានបែងចែកជាពីរ៖ អ្នកដែលប្រយុទ្ធ គេទៅប្រយុទ្ធ ចំណែកពួកខ្ញុំដែលប្រយុទ្ធមិនបាន គេឲ្យទៅធ្វើការនៅខាងក្រោយ តែការងារធ្ងន់បាទ។

**ស៖** តើលោកស្លៀកពាក់ឯកសណ្ឋានកងទ័ព ហើយសមាជិកដទៃទៀតនៅកងរបស់លោកស្លៀកពាក់ឯកសណ្ឋានកងទ័ពដែរ ឬក៏អត់ទេ?

**ឆ៖** សូមបញ្ជាក់ម្តងទៀត។ ខ្ញុំបាទស្តាប់អត់ច្បាស់។

**ស៖** តើលោកស្លៀកពាក់ខោអាវកងទ័ពដែរ ឬក៏អត់ទេ នៅពេលលោកនៅកំពង់ឆ្នាំង?

**ឆ៖** នៅកំពង់ឆ្នាំង ច្រើនស្លៀកខ្មៅ ពាក់ខ្មៅ ខោអាវផាឌិប។

[១៤:២៨:៥០]

**ស៖** តើខោអាវខ្មៅនេះជាឯកសណ្ឋានកងទ័ព ឬក៏មិនមែនទេ?

**ឆ៖** មិនមែនជាឯកសណ្ឋានកងទ័ពទេ។ គឺគេឲ្យស្លៀកខ្មៅពាក់ទាំងអស់គ្នា។ វៀរលែងតែអ្នកគេ ទ័ពនៅជួរមុខ គេស្លៀកពាក់ឯកសណ្ឋានទ័ព។

**ស៖** ដូច្នេះ គឺថាលោកមិនស្លៀកពាក់ខោអាវកងទ័ព មិនមានអាវុធ មិនអាចទៅប្រយុទ្ធសមរ-ភូមិបាន។ អ៊ីចឹង នៅកំពង់ឆ្នាំង តើគេចាត់ទុកលោកថាទាហានយ៉ាងដូចម្តេចទៅ បានអត់មានចំណុចទាំងអស់នេះ? ហេតុអីបានលោកចាត់ទុកខ្លួនឯងថាលោកគឺជាកងទ័ព?

**ឆ៖** នៅធ្វើការនៅកំពង់ឆ្នាំង គេបើកខោអាវផាឌិបឲ្យស្លៀកពាក់ អ្នកដែលធ្វើការនៅព្រលានទាំងអស់គ្នា អត់មានស្លៀកពាក់ឯកសណ្ឋានទ័ពទៀតទេ។

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីការងារជាច្រើនដែលលោកបានធ្វើ ខ្ញុំសូមដកស្រង់៖ "លោកធ្វើការពីម៉ោង៤ព្រលឹម រហូតដល់ម៉ោង១១ ហើយចាប់បន្តទៀតពីម៉ោង១១:៣០ ដល់ម៉ោង១១យប់។ ហើយនៅកន្លែងធ្វើការ លោកឃើញមនុស្សស្លាប់ដោយសារតែធ្វើការហួសកម្លាំងនិងអត់ឃ្លាន"។ នៅពេលដែលខ្ញុំអាននូវអ្វីដែលបានឆ្លើយ មានន័យថានៅពេលដែលនៅទីនោះ -- នៅពេលនោះលោកធ្វើការ១៨ម៉ោងក្នុងមួយថ្ងៃនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ត្រឹមត្រូវទេលោក លោកធ្វើការ១៨ម៉ោងក្នុងមួយថ្ងៃ?

**ឆ៖** ក្នុងនាមខ្ញុំបាទ ដែលគេឲ្យទៅលត់ដំ គឺធ្វើការយ៉ាងនេះ។ ពិតប្រាកដមែន។

[១៤:៣១:៤៩]

**ស៖** នៅពេលខ្លះខ្ញុំសួរលោកអំពីអំឡុងពេលវេលាពេលណាមួយ លោកបានឆ្លើយជូនតុលាការថា លោកនៅព្រលានយន្តហោះកំពង់ឆ្នាំងអស់រយៈពេលពីរបីខែ ហើយក៏មកភ្នំពេញ ៣ខែ ហើយត្រឡប់ទៅព្រលានយន្តហោះកំពង់ឆ្នាំងវិញពេញមួយអំឡុងពេលនោះតែម្តង។ ពាក់ព័ន្ធទៅនឹងចំនួនម៉ោងការងារ តើចំនួនម៉ោងការងារដែលលោកធ្វើពីរខែដំបូង និងទៅធ្វើពេលក្រោយទៀតនោះ វានៅតែដូចគ្នាទេ ឬក៏ថាពេលដែលលោកនៅពីរខែដំបូង ចំនួនម៉ោងការងារ វាតិចជាង វាស្រួលជាង ហើយក្រោយមកលោកធ្វើការពិបាក ឬក៏យ៉ាងម៉េច ដូចគ្នា ឬក៏កែប្រែ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំមេត្តាជ្រាប នៅពេលធ្វើការពីរខែគឺលត់ដំ ដូចខ្ញុំបាទបានរៀបរាប់។ តែក្រោយពេលរៀនសូត្រ ហើយវិលទៅវិញខ្ញុំបាទនៅខាងថ្លឹងដី។ ការងារខ្ញុំបាទបានធូរស្រាលបន្តិច។

**ស៖** ដូច្នេះ ពេលលោកនៅព្រលានយន្តហោះក្រោយមក គឺថាស្ថានភាពការងារនឹងប្រសើរជាងមុនបន្តិច។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតមែន ព្រោះនៅខាងថ្លឹងដី គេឱ្យតែបុកបង្ហាប់ដី ឬក៏រ៉ូឡូកិន កំណាត់ហាប់គេ បានខ្ញុំបាទយកកែវយកបោះ ហើយទៅថ្លឹង។

**ស៖** នៅពេលលោកនៅឯការដ្ឋានការងារនោះ ពេលលោកត្រឡប់ពីរៀនសូត្រនៅភ្នំពេញវិញ លោកថា លក្ខខណ្ឌការងារគឺថាគ្រាន់បើជាងមុន។ ចុះចំនួនម៉ោងការងារវិញ នៅតែដដែល ឬក៏អត់ទេ? តើចំនួនម៉ោងការងារ និងលក្ខខណ្ឌការងារនេះ គេនៅតែអនុវត្តចំពោះអ្នកដទៃ ឬក៏អត់ទេ?

[១៤:៣៤:៤៣]

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា នៅពេលនោះខ្ញុំបាទត្រូវបែកពីមិត្តផងគ្នា វានៅមួយកន្លែង។ ហើយការងារក៏បានប្រក្រតី ម៉ោងប្រាំពីរចូលធ្វើការ ម៉ោងដប់មួយសម្រាក និងម៉ោងមួយចូលធ្វើការម៉ោងប្រាំសម្រាក តែដល់មិត្តដទៃគេនៅធ្វើការដដែល។

**ស៖** ដូច្នេះ នៅពេលលោកត្រឡប់ពីរៀនសូត្រទៅវិញ ទៅធ្វើការនៅព្រលានយន្តហោះ។ តើចំនួនម៉ោងការងារហ្នឹង គឺថាមានការកែប្រែពីម៉ោងបួនព្រឹករហូតទៅកណ្តាលអធ្រាត្រ និងលោកបានទទួលការ -- ពេលម៉ោងការងារហ្នឹង គឺថាទៀងទាត់ប្រសើរជាងមុន។ ហើយចុះអ្នកដទៃទៀត ដូចលោកដែរឬក៏អត់ទេ?

**ឆ៖** អ្នកដទៃពុំបានដូចគ្នាទេ ព្រោះគេដកខ្ញុំបាទទៅនៅក្រុមខាងបច្ចេកទេស គេដាក់មួយកន្លែង ហើយមិត្តដែលរួមការងារទាំងអស់ហ្នឹង គេដកនៅមួយកន្លែងផ្សេងៗពីគ្នា បាទ។ នៅពេលនោះ អត់បានទាក់ទងគ្នាបានទេ។

**សៈ** សូមអរគុណ។ លោកបានឆ្លើយថាលោកបានឃើញមនុស្សស្លាប់ដោយសារតែធ្វើការហួសកម្លាំង។ សូមលោកពន្យល់អង្គជំនុំជម្រះបន្តិចមើល៍ លោកបានឃើញបែបណាខ្លះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គជំនុំ អ្នកខ្លះកំពុងតែរែកដី អ្នកខ្លះកំពុងតែកាប់ដី ដួលសន្លប់រហូតដល់ស្លាប់ក៏មាន មានច្រើន។ បាទ ដូចខ្ញុំឃើញ ដោយសារល្វើយកម្លាំង អស់កម្លាំង។

[១៤:៣៧:១៨]

**សៈ** លោកក៏បានឆ្លើយផងដែរថា អ្នកធ្វើការនៅព្រលានយន្តហោះហ្នឹង គឺស្លាប់ដោយអត់ឃ្លាន។ ខ្ញុំចង់សួរទៅលោក តើរបបអាហារហ្នឹង ម្នាក់ៗទទួលរបបអាហារបានប៉ុន្មាន? នៅក្នុងរយៈពេលពីរខែដំបូង មុនពេលគេបញ្ជូនលោកមករៀនភ្នំពេញ លោកគេឲ្យអ្វីខ្លះទៅឲ្យលោកហូប?

**ឆ៖** ហូបបាយ តែមិនគ្រប់គ្រាន់ទេ បាយថយ។

**សៈ** តើលោកចាំចំនួនរបបអាហារដែលលោកបានទទួលទេ មុនពេលទៅ -- មករៀនសូត្រនៅភ្នំពេញនេះ ចំនួនរបបអាហារដែលលោកបានទទួលប៉ុនណាដែរ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា ខ្ញុំបាទពុំបានចាំទេទានប្រុស។

**សៈ** នៅពេលលោកនិយាយថា គឺថាមនុស្សម្នា គឺថាទទួលអាហារមិនបានគ្រប់គ្រាន់ទេ។ តើគេមានសាច់ មានបន្លែ មានបាយដែរទេ ឬក៏គេមានអ្វីផ្សេង? គេមានសម្ល មានស៊ុប មានអីចឹងទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា សម្លគ្មានស៊ុប គ្មានការី គឺម្ជូរព្រឹក ម្ជូរល្ងាច តែប៉ុណ្ណោះទេ បាទ។ ទាំងអាហារ ត្រីសាច់ គឺមានតិចតួច។

**សៈ** តើពលករធ្វើការនៅព្រលានយន្តហោះដេកនៅឯណាដែរ? បន្ទាប់ពីចប់ម៉ោងការងារ តើពួកគាត់ទាំងអស់ហ្នឹងទៅសម្រាននៅឯណា?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា ខ្ញុំបានពុំស្គាល់ភូមិទេ តែនៅខាងលិចព្រលានយន្តហោះ ភូមិចាស់ដែលប្រជាជនរត់ចោល នៅជាក្រុមៗ។

**សៈ** នៅពេលដែលលោកទៅដល់លើកដំបូងនៅខែមករា ១៩៧៨ តើលោកអាចប៉ាន់ប្រមាណមើល៍ តើមានមនុស្សទាំងអស់ប្រហែលជាប៉ុន្មាននាក់ធ្វើការនៅព្រលានយន្តហោះនោះ?

[១៤:៤០:៤៥]

**ឆ៖** ខ្ញុំបាទ មិនប៉ាន់ប៉ាន់ស្មាន ព្រោះឃើញតែមនុស្សច្រើន។ បាទ ការងារខុសគ្នា។

**ស៖** បើសិនជាខ្ញុំបង្ហាញតួលេខ តើវាមាន ៥០, ៥០០, ៥.០០០, ៣.០០០, ១០.០០០ ក្នុងចំនួនទាំងអស់នេះ តួលេខដែលខ្ញុំប្រាប់នេះ វាស្ថិតនៅក្នុងតួលេខ មួយណាដែរ បើតាមលោកធ្វើការគណនាត្រួសៗមើល។

**ឆ៖** បើតាមគណនា ប៉ាន់ស្មាន ប្រហែលជា ៥០០នាក់ ដែលធ្វើការនៅកន្លែងនោះ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី។ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** បាទ ជម្រាបសួរម្តងទៀតលោកសាក្សី។ តើយើងអាចនិយាយបានដែរឬទេ ពេលដែលលោកត្រឡប់មកពីទទួលការបណ្តុះបណ្តាលនៅភ្នំពេញ ហើយត្រឡប់ទៅព្រលានយន្តហោះកំពង់ឆ្នាំងគឺលក្ខខណ្ឌជីវិតរបស់លោកនុ៎ងប្រសើរជាងមុន។ យើងអាចនិយាយអ៊ីចឹងបានដែរឬទេ?

**លោក កែវ លឿ៖**

**ឆ៖** នៅពេលដែលខ្ញុំបាទបានវិលត្រឡប់ទៅកំពង់ឆ្នាំងវិញ ខ្ញុំបាទធ្វើការនៅខាងថ្លឹងដី វាធូរស្រាលជាងការងារមុនពិតប្រាកដមែន។

**ស៖** អ្នកធ្វើការផ្សេងទៀតនៃកងរបស់លោកនោះ តើពួកគេនៅបន្តធ្វើការងារដដែល នៅពេលដែលលោកទៅដល់ការដ្ឋានកំពង់ឆ្នាំងហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** អង្គភាពដែលនៅធ្វើការខាងណោះ គេនៅធ្វើការដូចមុនដដែលបាទ។

**ស៖** បាទ ឥឡូវខ្ញុំចង់និយាយអំពីអនាម័យនៅពេលរយៈពេលពីរខែ ដែលលោកធ្វើការនៅទីនោះមុនពេលទទួលការបណ្តុះបណ្តាលនោះ។ តើពលករនៅក្នុងកងរបស់លោកនោះអាចងូតទឹក អាចមានបន្ទប់ទឹក ឬក៏មានការរៀបចំអីដើម្បីអនាម័យដែរឬទេ ដើម្បីឲ្យពួកពលករទាំងអស់នុំងមានសុខភាពល្អ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំថា មុនពេលដែលខ្ញុំបាទបានចូលទៅបណ្តុះបណ្តាល គ្មានអនាម័យសូម្បីតែម្ហូប គឺរុយរោម ហើយបក់រុយនោះ គឺហូប។ អត់មានអនាម័យទេ នេះសូមអង្គជំនុំមេត្តាជ្រាប។

[១៥:០៤:៥៣]

**ស៖** លោកបាននិយាយថាលោកបានឃើញមនុស្សស្លាប់ដោយអត់អាហារ និងធ្វើការហួសកម្លាំង។ តើសាកសពរបស់ពួកគាត់ហ្នឹង គេយកទៅធ្វើអី គេយកទៅកប់ ឬក៏គេធ្វើពិធីបុណ្យអីទេ ឬក៏គេយកទៅបូជា។ តើលោកដឹងទេ គេយកសាកសពរបស់ពួកគាត់ទៅធ្វើអ្វីដែរ?

**ឆ៖** នៅពេលនោះ ដែលមានមិត្តផងគ្នាស្លាប់ គេមិនបានយកទៅធ្វើបុណ្យទេ គេយកទៅកប់ចោល។

**ស៖** អ្នកធ្វើការនៅក្នុងកងរបស់លោកនោះ មានលទ្ធភាពចេញពីការដ្ឋានដើម្បីទៅមើលមិត្តភក្តិរបស់ខ្ញុំ ក្រុមគ្រួសាររបស់ខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំសូមបាទជម្រាបជូនអង្គជំនុំថា ពីកងមួយទៅកងមួយ មិនអាចទៅលេងផងគ្នាបានទេ។ អាហ្នឹងសូមអង្គជំនុំមេត្តាជ្រាប។

**ស៖** តើអ៊ីចឹងមានន័យថា មានអ្នកយាមដែលឃ្លាំមើល ឬក៏យាមអ្នកធ្វើការអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** គេមានអ្នកយាមចាំឃ្លាំមើលនៅពេលណាដែលយើងដើរចេញពីអង្គភាព គេថាយើងខ្មាំងមានតែប៉ុណ្ណោះបាទ។

**សៈ** តើអ្នកយាមហ្នឹងមានអាវុធដែរឬទេ?

**ឆៈ** អ្នកយាមនៅអង្គភាពនោះគ្មានកាន់កាំភ្លើងទេ ដែទទេដូចគ្នា។

**សៈ** តើអ្នកយាមហ្នឹងគេស្លៀកពាក់សំលៀកបំពាក់ខុសពីពលករ ឬក៏យ៉ាងណា? ចង់និយាយឯកសណ្ឋានគេហ្នឹង ខុសពីពលករ ឬយ៉ាងណា?

**ឆៈ** អ្នកយាមមានឯកសណ្ឋានខុសពីយើងពលករ គឺឯកសណ្ឋានទ័ព។

[១៥:០៨:២៥]

**សៈ** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាអ្នកយាមមានប៉ុន្មាននាក់? បើសិនជាមានកម្មករ៣០ ឬ៤០នាក់ ដែលធ្វើការនៅកន្លែងណាមួយនោះ តើគេដាក់អ្នកយាមម្នាក់ ឬក៏លើសពីម្នាក់? លោកអាចជម្រាបជូនតុលាការដែរឬទេ យើងបើគិតពីសមាមាត្រហ្នឹង ចំនួនកម្មករ៣០-៤០នាក់អ៊ីចឹង តើគេត្រូវដាក់អ្នកយាមប៉ុន្មាននាក់ដែរ?

**ឆៈ** ក្នុងចំនួនមនុស្ស៣០-៤០នាក់ គេដាក់ពីរនាក់ ប៉ុន្តែអ្នកយាមមិនអាចនៅមួយកន្លែងបានទេ គេដើរចុះ ដើរឡើង ពេលដែលយើងសម្រាក។

**សៈ** តើអ្នកយាមខ្លះហ្នឹងមកពីកងលោកដែរឬទេ បានន័យថាអង្គភាព ក-៤?

**ឆៈ** នៅក្នុងអង្គភាពយើងខ្ញុំអត់មានចេញយាមទេ។

**សៈ** លោកបាននិយាយថា អ្នកធ្វើការនៅក្នុងអង្គភាព៤៥០ហ្នឹងធ្វើការនៅលើព្រលានយន្តហោះ។ តើនៅក្នុងកងពលហ្នឹងមានអ្នកមួយចំនួនជាអ្នកយាមដែរឬទេ?

**ឆៈ** ខ្ញុំបាទពុំបានដឹងទេ កងពលគេផ្សេង ព្រោះមិនអាចយើងដើរទៅលេងទាក់ទងគ្នាបានបាទ ដឹងតែកន្លែងរបស់ខ្លួន។

[១៥:១០:៤៥]

**សៈ** តើលោកដឹងទេថា អង្គភាពយោធាណាទទួលបន្ទុកព្រលានយន្តហោះហ្នឹងដែរឬទេ? លោកដឹងថាអង្គភាពណាជាអ្នកទទួលបន្ទុកការងារនៅព្រលានយន្តហោះហ្នឹងដែរឬទេ?

**ឆៈ** ខ្ញុំបាទពុំបានដឹងច្បាស់អំពីអ្នកដឹកនាំនៅក្នុងអង្គភាពធ្វើព្រលានយន្តហោះទេ ពុំបានចាំទេ។

**សៈ** សំណួរចុងក្រោយទាក់ទងនឹងប្រធានបទនេះ។ តើលោកដឹងដែរឬទេ ថាតើអ្នកយាមនៅលើការដ្ឋានព្រលានយន្តហោះទាំងអស់ហ្នឹង ចំណុះឲ្យអង្គភាពណាដែរ?

**ឆៈ** ខ្ញុំបាទពុំបានដឹងទេ អ្នកយាមនេះឃើញតែពេលយប់ គេដើរតាមមុខកន្លែងយើងសម្រាក។

**ស៖** ឥឡូវត្រឡប់មកនិយាយអំពីពេលវេលាដែលមុនពេលដែលលោកទទួលការបណ្តុះបណ្តាល ហើយនិងនិយាយអំពីអង្គភាពលោក។ តើអ្នកយាមហ្នឹងធ្វើការក្នុងលក្ខខណ្ឌដូចកងរបស់លោកដែរឬទេ? ហើយម៉ោងធ្វើការងារជាដើមហ្នឹងដូចគ្នាដែរឬទេ?

**ឆ៖** អ្នកយាមនេះ ពេលថ្ងៃមិនដែលឃើញទេ មិនដឹងគេនៅកន្លែងណា ហើយក៏មកពីអង្គភាពណា មិនដែលស្គាល់។

**ស៖** លោកនិយាយថា ខ្វះអាហារនៅពេលដែលលោកធ្វើការនៅទីនោះជាលើកទី១។ លោកនិយាយថា មានអ្នកស្លាប់ដោយធ្វើការហួសកម្លាំងនិងដោយអត់អាហារ។ តើលោកបានឃើញអ្នកយាមនោះ ស្លាប់ដោយធ្វើការហួសកម្លាំង ហើយនិងដោយខ្វះអាហារដែរឬទេ?

**ឆ៖** អ្នកដែលទៅយាមពេលយប់ មិនដែលឃើញគេស្លាប់ទេបាទ។

[១៥:១៤:០៥]

**ស៖** ខ្ញុំសួរលោកនូវអ្វីដែលលោកបានឃើញទេ។ អ៊ីចឹងខ្ញុំសួរលោក ថាតើមានធ្លាប់ឃើញអ្នកយាមស្លាប់ដោយអត់អាហារ ឬដោយធ្វើការហួសកម្លាំងដែរឬទេ? ឬក៏លោកធ្លាប់ឃើញតែអ្នក តែកម្មករទេដែលស្លាប់ដោយអត់អាហារ និងធ្វើការហួសកម្លាំងនេះ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គជំនុំម្តងទៀត។ អ្នកដែលយាមកាមមិនដែលឃើញស្លាប់ទេ ដែលឃើញស្លាប់ដោយសារអត់អាហារ គឺមានតែពលករដូចគ្នាបាទ។

**ស៖** បើសិនជាកម្មករមិនស្រួលខ្លួន ឬក៏ធ្លាក់ខ្លួនឈឺ តើគេអាចទទួលការព្យាបាលបានដែរឬទេ? ហើយមានគេឲ្យថ្នាំសង្កូវអីដែរឬទេ?

**ឆ៖** ចំពោះបងប្អូនពលករដូចគ្នា ឈឺទាល់តែក្រោកលែងរួចបានគេហៅពេទ្យឲ្យយកទៅកន្លែងពេទ្យ។

**ស៖** នៅពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះនោះ តើលោកអាចត្អូញត្អែរថាហូបមិនឆ្អែតដែរឬទេ? តើលោកអាចត្អូញត្អែរថា ការងារហ្នឹងធ្ងន់ធ្ងរហួសពេកដែរឬទេ? តើលោកអាចត្អូញត្អែរពីការដែលលក្ខខណ្ឌអនាម័យនោះមិនគ្រប់គ្រាន់ ដោយសារលោកមិនអាចសម្អាតខ្លួនបាន ងូតទឹកបាន។ តើលោកមានលទ្ធភាព ឬក៏មានសិទ្ធិសេរីភាពនិយាយអំពីបញ្ហាកង្វះខាតទាំងអស់នេះ ដោយមិនមានការភ័យខ្លាចដែរឬទេ?

[១៥:១៦:៥២]

**ឆ៖** ក្នុងការហូបចុកដែលខ្វះអនាម័យ មិនដែលបានលាន់មាត់ទេ សូម្បីតែស្លម្ភូរត្រកួន គេដាក់ចង្រឹតក៏ចេះតែទ្រាំលេប ដោយសារខ្លាចអំណាចគេបាទ។

**ស៖** ហេតុអ្វីក៏លោកមិនត្អូញត្អែរបាន? អាចនិយាយពីបរិយាកាសនៅលើការងារនៅលើការដ្ឋានហ្នឹងបានទេ? តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានលោកមិនបានត្អូញត្អែរ ដោយសារខ្លាចមានបញ្ហាដល់ខ្លួន?

**ឆ៖** ក្នុងសភាពដែលយើងត្អូញត្អែរ គេថាយើងទម្រន់ យើងខ្សែខ្សោយ។ ដូច្នេះ កិច្ចការងារទាំងឡាយគឺខាំមាត់សង្កត់ចិត្ត មិនបានតបតនឹងគេ ទោះបីគេឱ្យហូបយ៉ាងណាក៏ដោយ ធ្វើការយ៉ាងណាក៏ដោយ សុខចិត្តខាំមាត់សង្កត់ចិត្ត ឱ្យតែបានរស់ក្នុងមួយគ្រាបាទ។

**ស៖** បាទ ដោយសង្ខេប ទាក់ទងទៅនឹងសកម្មភាពនៅលើព្រលានយន្តហោះនោះ តើអ្វីដែលលោកចាំមុនពេលដែលលោកទទួលការបណ្ដុះបណ្ដាល ហើយនិងក្រោយពេលលោកការបណ្ដុះបណ្ដាល តើលោកអាចជម្រាបតុលាការជូនបានទេថា ការងារដើម្បីសង់ព្រលានយន្តហោះហ្នឹង មានការងារអ្វីខ្លះនៅលើការដ្ឋានហ្នឹង? និយាយថាសកម្មភាពដែលអាចធ្វើបានដោយជោគជ័យនៅពេលនុ៎ងនោះ សកម្មភាពអីខ្លះ ការងារអីខ្លះ ដែលគេឱ្យកម្មករធ្វើបាន?

[១៥:១៩:១៩]

**ឆ៖** នៅក្នុងសកម្មភាពការងារធ្វើព្រលានយន្តហោះ គឺមានច្រើនៗប្រភេទ។ មានអ្នកខ្លះខាងជីករណ្ដៅតាមឫស អ្នកខ្លះត្រូវជីកស្មៅ ហើយមានមួយចំណែកគឺមានត្រាក់ទ័ររួសដីទៅចាក់ ហើយមានមួយចំណែកគឺផ្នែករៀបថ្មល់គ្រឹះ ថ្មល់គោលពីអង្គភាពផ្សេងៗពីគ្នា។ បាទ មានច្រើន ខ្ញុំបាទមិនបានចាំអស់ទេ សូមអង្គជំនុំជម្រះមេត្តាជ្រាប។

**ស៖** ចំពោះលោកផ្ទាល់ មុននឹងទៅទីក្រុងភ្នំពេញនោះ លោក -- កាលនោះត្រូវបោចស្មៅ។ តើលោកត្រូវធ្វើអីផ្សេងទៀតទេ មុនពេលដែលរៀនហ្នឹង មុននឹងរៀនយកចំណេះខាងអ្នកស្ទង់ដីហ្នឹង លោកមានធ្វើអីទៀតទេ ក្រៅពីដកស្មៅហ្នឹង?

**ឆ៖** មុនពេលខ្ញុំបាទទៅរៀននៅភ្នំពេញ មានតួនាទីដកស្មៅ ជីករណ្ដៅតាមឫស។

**ស៖** តើអ្នកផ្សេងទៀតនៅក្នុងកងរបស់លោកហ្នឹង ត្រូវធ្វើការងារដូចគ្នានឹងលោកដែរ ឬក៏យ៉ាងណា?

**ឆ៖** អ្នកនៅកន្លែងនោះ គឺធ្វើការដូចៗគ្នា។

**ស៖** តើជើងរបស់លោកនោះ មានបញ្ហាដែរឬទេ ព្រោះលោកនិយាយថាលោកបាក់ជើង។ តើលោកមានការឈឺចាប់ លោកឈឺជើងដែរឬទេ ពេលដែលលោកធ្វើការនៅពេលនោះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គជំនុំជម្រះ ធ្វើការនៅពេលនោះទៅទាំងចិត្ត។ ពេលឈរឈឺ ជើងខ្ញុំបាទមិនធានាដូចជើងអ្នកដែលជាទេ ពេលដែលធ្វើការគឺខ្ញុំបាទមានទឹកភ្នែកម្តងៗ ដោយសារជើងរបស់ខ្លួន។

[១៥:២២:២៥]

**ស៖** តើលោកទទួលអារម្មណ៍យ៉ាងណាដែរ នៅពេលដែលលោកបង្ខំចិត្តទៅដកស្មៅ ហើយលោកឈឺជើង របួសជើង លោកមិនមានអាហារគ្រប់គ្រាន់ សម្រាន្តមិនគ្រប់គ្រាន់ មិនមានប្រព័ន្ធអនាម័យគ្រប់គ្រាន់? តើក្នុងលក្ខខណ្ឌបែបនេះ លោកទទួលអារម្មណ៍យ៉ាងណាដែរ? លោកអាចពិពណ៌នាអំពីអារម្មណ៍របស់លោកជូនតុលាការបន្តិចបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការមេត្តាសូមមេត្តាជ្រាប ខ្ញុំបាទទទួលអារម្មណ៍ថា ខ្ញុំបាទហាក់ដូចជាមនុស្សស្លាប់នៅពេលនោះ។ អត់មានសង្ឃឹមថា បានរស់រានមានជីវិត ទៅជួបអ្នកមានគុណរបស់ខ្ញុំបាទទេ។ នឹកឃើញថា ថ្ងៃណាមួយហ្នឹងគឺត្រូវស្លាប់ដោយសារការងារពលកម្ម ឬក៏នឹងអាហារមិនគ្រប់គ្រាន់។ ហើយនឹកឃើញថា នឹកឪពុកម្តាយរាប់ឆ្នាំមិនដែលបានឃើញ ឬជំណឹងដោយសារបែកពីឪពុកម្តាយ។ រាល់ថ្ងៃជួនកាលមានការដេកយំម្នាក់ឯង ដោយនឹកឪពុកនិងម្តាយ ហើយណាការងារខ្លួនក៏ធ្ងន់ធ្ងរ។ នេះខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាបទាន។

**ស៖** តើអ្នកយាមទទួលការប្រព្រឹត្តខុសគ្នាពីពលករ ហើយនិងពួកធ្វើការជាមួយលោកដែរឬទេ? ឬក៏អ្នកយាមនេះធ្វើការក្នុងលក្ខខណ្ឌដូចពួកលោកដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាប ចំពោះអ្នកយាមមិនដែលឃើញគេធ្វើការជាមួយពលករទេ ឃើញមួយតែពេលយប់ ពេលដែលពលករចូលសម្រាក ហើយមិនអាច -- មិនមានសិទ្ធិនិយាយជាមួយគេបានទេ។ បាទ នេះសូមអង្គជំនុំមេត្តាជ្រាប។

[១៥:២៥:៣៥]

**ស៖** សូមអរគុណ។ លោកសាក្សី ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីប្រធានបទមួយទៀត។ ឥឡូវខ្ញុំចេញពីប្រធានបទលក្ខខណ្ឌការងារដ៏លំបាកនៅលើការដ្ឋាន។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីការចាប់ខ្លួនវិញម្តង។ លោកបាននិយាយថា មុនទៅដល់ព្រលានយន្តហោះនោះ មានការចាប់ខ្លួននៅក្នុងកងរបស់

លោករួចទៅហើយ។ ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកប្រាប់ថា តើលោក -- ពេលដែលលោកទៅដល់ព្រលានយន្តហោះនោះ ហ្នឹងហើយឬដែលមានការចាប់ខ្លួន ឬក៏មុនពេលដែលលោកទៅដល់ព្រលានយន្តហោះ?

ឥឡូវ ខ្ញុំសូមអាន និងអានកំណត់ហេតុស្ដាប់ចម្លើយរបស់លោកដែលលោកបានផ្ដល់ជូនទៅឲ្យអ្នកស៊ើបអង្កេត ខ្ញុំសូមអានផ្នែកហ្នឹង ហើយបន្ទាប់មកយើងនឹង -- ខ្ញុំនឹងសួរសំណួរទៅលោក។ បាទ ខ្ញុំនិយាយពីកំណត់ហេតុស្ដាប់ចម្លើយដែលខ្ញុំបានលើកហើយលោកប្រធាន អម្បាញ់មិញនេះ។ គឺលោកបាននិយាយថា ឡានមកចាប់មនុស្សរាល់យប់ ចាប់ប្រហែល -- រាល់ដងនោះ ចាប់២០នាក់។ ហើយនៅពេលប្រជុំ ឈ្មោះអ្នកទាំងអស់នោះ គេប្រាប់ឈ្មោះ គេហៅឈ្មោះហើយ ឲ្យចេញមក ហើយគេចាប់ភ្លាមតែម្ដង។ ចំពោះកងរបស់លោកវិញ មានតែមនុស្ស១៤នាក់ទេ ដែលនៅរស់រានមានជីវិតនោះ នៅសល់នោះ។ តើជាការត្រឹមត្រូវដែរឬទេ គឺថានៅពេលដែលលោកនៅព្រលានយន្តហោះហើយនោះ មានការចាប់ខ្លួនអ៊ីចឹង គឺថារាល់យប់ហ្នឹង មានគេមកចាប់មនុស្ស?

[១៥:២៧:៣៣]

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការសូមមេត្តាជ្រាប។ ពេលដែលចាប់ច្រើននេះ នៅពេលដែលខ្ញុំបាទនៅក្នុងអង្គភាព៣១៧ នៅឃ្មួញកប់ស្រូវ។ នេះចាប់ច្រើន ដែលថាមួយកងនៅសល់១៤នាក់។ នេះសូមអង្គតុលាការមេត្តាជ្រាបទាន។

**ស៖** តើលោកកំពុងតែនិយាយថា ក្នុងកងលោកដែលមានមនុស្ស៤០០នាក់នោះ មុនពេលដែលលោកទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺនៅសល់តែ១៤នាក់ទេដែលនៅរស់នោះ ដែលរួចខ្លួន ឬក៏លោកចង់និយាយថាក្រោយឆ្នាំ១៩៧៩ លោកបានជួបមុខមនុស្សអ្នកធ្វើការជាមួយលោកនោះតែ១៤នាក់ប៉ុណ្ណោះ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំជម្រះ។ នៅពេលក្រោយឆ្នាំ៧៩ គឺបានជួបគ្នាតែ១៤នាក់ដែលទៅពីខេត្តជាមួយគ្នាបាទ។

[១៥:១៩:៣៣]

**ស៖** នៅក្នុងកងក-៩របស់លោក ក្រៅពីអ្នកៗទាំង១៤នាក់នេះ តើលោកធ្លាប់ជួបអ្នកផ្សេងទៀតទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ សូមមេត្តាជ្រាប។ ក្រៅពីអ្នក១៤នាក់ ដែលគេចាប់ទៅនោះ មិនដែលឃើញវិលមកវិញ។ នេះសូមមេត្តាជ្រាប។

**ស៖** បើយើងនិយាយអំពីរយៈពេលដែលគេចាប់មនុស្សច្រើននៅក្នុងកងរបស់លោក គឺថាមុនពេលដែលលោកទៅដល់ព្រលានយន្តហោះកំពង់ឆ្នាំង។ តើនៅព្រលានយន្តហោះនោះ មានការចាប់ខ្លួនដែរឬទេ ដូចគ្នាដែរឬទេ? ហើយមានឡានធំហ្នឹងគឺមកព្រលាន មកលើការដ្ឋាននេះ មកចាប់ខ្លួនដូចដែលអង្គាល់ដែលលោកធ្វើការនៅក-៤ ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គជំនុំជម្រះ។ នៅវរៈក-៤ ក៏ដូចជា៣១៧ គេមានចាប់ច្រើន។ តែដល់ទៅកំពង់ឆ្នាំង ខ្ញុំបាទមិនសូវបានឃើញទេ នេះសូមមេត្តាជ្រាប។

**ស៖** តើលោកធ្លាប់ឃើញមានការចាប់ខ្លួននៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងដែរឬទេ? បើលោកធ្លាប់ឃើញ តើមានរឿងអ្វីកើតឡើងដែរនៅពេលនោះ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការសូមមេត្តាជ្រាប។ នៅកំពង់ឆ្នាំងមានឃើញ ប៉ុន្តែតិចជាងនៅឃ្មួញកប់ស្រូវ ដែលគេថា "ខ្សែខ្មាំងចាប់មិនអស់"។ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** តើលោកកំពុងតែនិយាយថា មានការចាប់ខ្លួននៅកំពង់ឆ្នាំង គឺថាចាប់អ្នកដែលនៅក្នុងកងរបស់លោក ទោះបីថាការចាប់ខ្លួនហ្នឹងវាមិនចាប់ខ្លួនញឹកញាប់ដូចនៅកន្លែងផ្សេងក៏ដោយចុះ។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** អ្នកដែលគេចាប់ខ្លួននៅកំពង់ឆ្នាំង មិនមានការញឹកញាប់ដូចនៅឃ្មួញកប់ស្រូវទេ។

[១៥:៣៣:២០]

**ស៖** តើលោកអាចពន្យល់បានដែរឬទេថា ទោះបីជាការចាប់ខ្លួននោះវាមិនញឹកញាប់ក៏ដោយ។ តើថាការចាប់ខ្លួននៅកំពង់ឆ្នាំងនោះ គេធ្វើយ៉ាងដូចម្ដេចដែរ បើតាមអ្វីដែលលោកឃើញនោះ?

**ឆ៖** តាមដែលខ្ញុំបាទឃើញ ដែលគេចាប់មួយៗ គេហៅប្រជុំគ្នាហើយ គេហៅឈ្មោះអ្នកដែលត្រូវគេចាប់ខ្លួនបាទ។

**ស៖** តើលោកដឹងដែរឬទេថា តើគេនាំអ្នកដែលគេចាប់ខ្លួននោះ ទៅទិសណាដែរ?

**ឆ៖** ខ្ញុំបាទពុំបានដឹងថា គេនាំអ្នកដែលចាប់ខ្លួននោះទៅខាងណាទេ។

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីពេលដែលលោកមកធ្វើការនៅឃ្មួញនិងកប់ស្រូវ។ លោកបាននិយាយថា មានការចាប់ខ្លួនញឹកញាប់នៅក្នុងកងរបស់លោក អង្គាល់ដែលលោកធ្វើការនៅទីនោះ។ ឥឡូវខ្ញុំសូមអានអ្វីដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/467, ជាភាសាអង់គ្លេសា 0005 -- បាទ ជាភាសាបារាំងគឺ

00205077។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើ -- យើងនិយាយអំពីក-៤ លោកបានឆ្លើយថា៖ “មានទាហាន ៦០០នាក់នៅក-៤នោះ ហើយគេបង្ខំឲ្យយើងធ្វើការ គឺដាំស្រូវ៤ហិកតាក្នុងមួយថ្ងៃ ទាំង៦០០នាក់ជាង ហ្នឹងត្រូវធ្វើយ៉ាងនោះ។ ខ្ញុំឃើញហ្នឹងដោយផ្ទាល់ភ្នែកតែម្តង មានមនុស្ស៣៦-៣៧នាក់ស្លាប់ កាលនោះ តាទី ហើយនិងតា -- គាត់កាន់ក-៤ ហើយក្រោយមក គាត់ត្រូវបានគេចាប់ខ្លួន”។ ឥឡូវ ខ្ញុំសូមនិយាយ អំពីលក្ខខណ្ឌការងារនៅឃ្លាំងនិងកប់ស្រូវហ្នឹង។ ខ្ញុំសូមនិយាយអំពីការចាប់ខ្លួនផងដែរ។ នៅ -- ហើយ លោកបាននិយាយថា គេសួរថា “ហេតុអីបានគេចាប់ខ្លួនអ្នកទាំងអស់ហ្នឹង?” លោកឆ្លើយថា “ឃើញគេ ចាប់មនុស្សច្រើនណាស់ ដោយដឹកតាមឡានឡង់រ៉ូវើរ ហើយគេមកចាំបួនដប់នាក់រាល់យប់។ គេមក ចាប់ដល់កន្លែងតែម្តង។ នៅពេលខ្លះហ្នឹង គេហៅទៅភ្នំពេញដើម្បីចាប់។ គេចោទថា ពួកអ្នកដែលត្រូវ ចាប់ទាំងអស់នោះៗ គឺជាខ្មែរ សេ.អ៊ី.អា។ នៅពេលចាប់ហ្នឹង គេចាប់ចងស្លាបសេក ហើយច្រកក្នុងបាវ រួច បោះចូលក្នុងឡានតែម្តង”។ តើហ្នឹង គឺជាចាប់ខ្លួនហ្នឹងនៅក្នុងរយៈពេលដែលលោកនៅកំពង់ឆ្នាំង ឬ នៅឯណា? ពេលដែលគេចាប់ខ្លួនច្រើនជាងគេហ្នឹង?

[១៥:៣៨:២១]

**ឆ៖** នៅពេលដែលគេចាប់ខ្លួនច្រើនជាងគេ គឺនៅឃ្លាំង ចាប់ច្រើនជាងគេ។

**ស៖** តើលោកអាចនិយាយដោយប្រើពាក្យពេចន៍របស់លោកដោយផ្ទាល់ជូនតុលាការ ថាតើគេ ចាប់ខ្លួនមនុស្សយ៉ាងដូចម្តេចដែរ ហើយលោកបានឃើញអ្វីខ្លះពេលដែលគេចាប់ខ្លួនមនុស្សនោះ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជម្រាបជូនអង្គតុលាការ សូមមេត្តាជ្រាប នៅពេលដែលគេចាប់ម្តងៗគេ ហៅប្រជុំទាំងអស់ ឲ្យតម្រង់ជាជួរ ហើយគេហៅឈ្មោះអ្នកដែលត្រូវចាប់ខ្លួនចេញមកមុខ។ ពេលដែល គេចងស្លាបសេកហើយគេឲ្យអង្គុយ គេបង្ហោះបាវទៅលើផាត់ផ្តួលចងមាត់បាវលើកបោះដាក់ឡាន។ នេះសូមអង្គតុលាការមេត្តាជ្រាបនៅពេលនោះ។

**ស៖** តើអ្នកធ្វើការនៅក្នុងកងរបស់លោកទាំងអស់នោះ ត្រូវបានគេកោះទៅប្រជុំ ហើយអ្នក ផ្សេងទៀតហ្នឹង ឃើញការចាប់ខ្លួនហ្នឹងដែរ ឬក៏មានតែអ្នកដែលត្រូវគេចាប់ខ្លួនទេ ដែលគេហៅទៅ ប្រជុំនុ៎ង? តើលោកអាចពន្យល់អំពីអ្វីដែលប្រព្រឹត្តទៅក្នុងពេលការចាប់ខ្លួនហ្នឹងបានដែរឬទេនៅឃ្លាំង កប់ស្រូវហ្នឹង?

**ឆ៖** នៅឃ្លាំងកប់ស្រូវ ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការសូមមេត្តាជ្រាប។ នៅពេលដែលគេ ទៅចាប់ គេប្រមូលទាំងអស់ប្រជុំ មិនមែនហៅតែអ្នកដែលត្រូវចាប់ទេ គឺគេហៅប្រជុំទាំងអស់គ្នាឲ្យ

ឈរតម្រង់ជួរ ហើយគេហៅឈ្មោះអ្នកដែលត្រូវចាប់ខ្លួនទៅជួរមុខ។ បាទ នេះសូមអង្គតុលាការមេត្តាជ្រាបនៅពេលនោះ។

**ស៖** នៅរយៈពេលដែលគេចាប់ខ្លួនច្រើនជាងគេហ្នឹង លោកនិយាយថាក្នុងមួយថ្ងៃគេចាប់ប្អូនដប់នាក់ មួយយប់ៗហ្នឹងចាប់ប្អូនដប់នាក់។ តើជាការត្រឹមត្រូវដែរឬទេ គឺថាអ្នកធ្វើការក្នុងកងលោកទាំងអស់គ្នាហ្នឹងត្រូវបានគេកោះហៅរាល់យប់ ហើយអ្នកដែលត្រូវគេចាប់ខ្លួនហ្នឹង គេដកចេញពីអង្គប្រជុំ។ លោកចង់និយាយអ៊ីចឹងមែនទេ?

[១៥:៤១:៤៣]

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** បើតាមអ្វីដែលលោកចាំ ទោះបីជាពេលប្រជុំនោះមានអ្នកចូលរួមប្រជុំកាន់តែតិចទៅៗក៏ដោយហ្នឹង តើនៅក្នុងកងលោកនោះ អ្នកទៅចូលប្រជុំហ្នឹងមានប៉ុន្មាននាក់ដែរ គឺ១០នាក់ ២០នាក់ ៣០នាក់ ៤០នាក់? ហើយកងគេផ្សេងទៀតហ្នឹងក៏ចុះដូចគ្នាដែរ អ្នកដែលចូលរួមប្រជុំហ្នឹង ឬក៏យ៉ាងណាលោកអាចពន្យល់តុលាការបន្តិចបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាប មិនមែនតែកងខ្ញុំបាទមួយទេ គឺគ្រប់កងទាំងអស់ក្នុងអង្គភាព៣១៧ គឺចេះតែថយចុះគ្រប់កងទាំងអស់។ នេះសូមអង្គតុលាការមេត្តាទានជ្រាប។

**ស៖** តើលោកអាចជម្រាបជូនតុលាការអំពីចំនួនប្រជាជន -- ចំនួនអ្នកដែលត្រូវចូលរួមក្នុងកិច្ចប្រជុំនោះបានទេ ១០០នាក់ ឬក៏២០នាក់ ឬក៏៣០នាក់? តើចំនួនអ្នកចូលប្រជុំនេះ វាច្រើនប៉ុនណា ឬក៏វាមានចំនួនតិចប៉ុនណា លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទមិនដឹងចេះប៉ាន់ស្មានយ៉ាងណា ព្រោះវាច្រើនគ្នាយូរៗទៅចេះតែបាត់ទៅៗបាទ។

[១៥:៤៣:៥៥]

**ស៖** តើអង្គប្រជុំហ្នឹង អ្នកណាជាអ្នកកោះហៅ អ្នកណាជាអ្នកកោះហៅឲ្យទៅប្រជុំ មេកងមេអង្គភាពក-៤ ឬក៏មេអង្គភាពផ្សេងទៀត? តើអ្នកណាជាអ្នកមានសិទ្ធិកោះប្រជុំ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាប នៅអង្គភាព៣១៧នេះ អត់មានក-៤ទៀតទេ គឺ៣១៧ ដែលគេចាប់ច្រើននោះគឺ៣១៧។ ហើយថ្នាក់ដឹកនាំ ខ្ញុំបាទពុំបានស្គាល់ឈ្មោះគេទេ ព្រោះពួកនោះ គឺភូមិភាគនិរតី គេក្តាប់ទាំងអស់។

[១៥:៤៥:00]

**សៈ** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកៗបានផ្តល់ព័ត៌មានច្រើនថា តើការចាប់ខ្លួននេះវាកើតឡើងដោយរបៀបណា។ ខ្ញុំសូមអានជូនលោកស្តាប់ក្រែងជួយរំឭកដល់ការចងចាំរបស់លោកទៅលើព្រឹត្តិហេតុទាំងអស់នោះ។ គេបានសួរលោកថា “អ្នកណាជាអ្នកមកចាប់ខ្លួន?” លោកឆ្លើយថា៖ “ពួកសន្តិសុខ គេជិះឡានមកៗពីព្រៃសនិងមកពីទួលស្លែង។ ខ្ញុំដឹងព្រៃសនិងទួលស្លែងហ្នឹង គឺថាគឺជាគុកដោយសារថាមេដឹកនាំតែងតែនិយាយគំរាមកំហែងថា អាណាម្នាក់ខ្ជិល ហើយនិង ឬក៏អាណាធ្វើអ្វីខុសគឺថានឹងបញ្ជូនខ្លួនអ្នកឯង ទៅព្រៃស ឬទួលស្លែងហើយ។ នៅក្នុងឆ្នាំ១៩៧៦ គេចាប់ផ្តើមចាប់ថ្នាក់ដឹកនាំគឺពួកខាងភូមិភាគនិរតីជាអ្នកមកចាប់ ហើយក្នុងឆ្នាំ១៩៧៧ គេចាប់មេដឹកនាំមកពីភូមិភាគឧត្តរ។ គេចាប់មេដឹកនាំទាំងអស់មកពីថ្នាក់កងពលចុះរហូតទៅដល់មេក្រុម។ ខ្ញុំបានឃើញផ្ទាល់ គេចាប់ តាទីដែលជាប្រធាន ក-៤, តាសែន អនុប្រធាន និងតារុំ ដែលទទួលខុសត្រូវខាងផ្នែកភស្តុភារ។ មុននឹងចាប់ខ្លួន គេហៅមកប្រជុំទ័ព ហើយគេហៅមកហ្នឹងមុនគេ។ ខ្ញុំមិនដឹងអ្នកណាឲ្យចាប់ទេ ប៉ុន្តែខ្ញុំឃើញ -- ខ្ញុំអត់ឃើញអ្នកដែលគេចាប់ខ្លួនហ្នឹង គឺថាត្រឡប់មកវិញទេ។” តើត្រឹមត្រូវទេ ដែលថាលោកបានឃើញមេកង អនុប្រធានកង -- មេអង្គភាព អនុអង្គភាព និងតារុំ ដែលជាអ្នកទទួលខាងភស្តុភារហ្នឹង គឺត្រូវបានគេចាប់ខ្លួននៅក្នុងថ្ងៃនោះ លោកបានឃើញមែន ឬក៏អត់ទេ?

**ឆៈ** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការថា នៅពេលនោះគឺខ្ញុំបាទនៅស្តាប់ការប្រជុំនឹងគេ បានឃើញដោយពិតប្រាកដ ឥតមានលាក់លៀមបាទ។

[១៥:៤៧:៣៦]

**សៈ** ហើយគេក៏បានសួរលោកនៅក្នុង ឯកសារ E3/467 និងអង់គ្លេស 00205078, ខ្មែរ 00170619, បារាំង 00205077។ គេសួរលោកដូចតទៅ៖ “ក្រៅពីមេៗទាំងបីនាក់ហ្នឹង តើលោកបានឃើញគេចាប់មេៗដទៃទៀតទេ?” លោកឆ្លើយថា៖ “ខ្ញុំបានឃើញគេចាប់ប្រធានកងធំឈ្មោះ តាស៊ីម និងតាវ៉ែង”។ ឆ្នាំ១៩៧៧ គេបានចាប់ តាអឿន គេបានប្រកាសថា តាអឿន, តាគីម និងតាយៀត ជាខ្សែសេ.អ៊ី.អា គេប្រជុំក្នុងខែកក្កដា ឆ្នាំ១៩៧៧ ដែលពេលនោះ គេបានប្រកាសថា សូមដកស្រង់៖ “មេអ្នែងហ្នឹងជា សេ.អ៊ី.អា ជាពួកក្បត់ តើពួកអ្នែងគិតយ៉ាងម៉េច?” បញ្ចប់ការដកស្រង់។ ពេលមេៗមកពីភូមិឧត្តរត្រូវបានគេចាប់ខ្លួនអស់ ខាងពួកនិរតីជាអ្នកមកកាន់កាប់ជំនួស។ បន្ទាប់ពីពេលនោះមក គេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំង។ សំណួរដំបូងរបស់ខ្ញុំ តើត្រឹមត្រូវដែរឬក៏អត់ទេ ដែលថាលោកបានឃើញ តាស៊ីម

និង តាវែង ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ ថាខ្ញុំបាទបានឃើញ ពិតប្រាកដមែននៅពេលនោះ។

**ស៖** សូមអរគុណលោក។ ទៅតាម -- ខ្ញុំចង់ស្វែងយល់ឲ្យបានច្រើនបន្តិច។ នៅឯឃ្លាំងកប់ស្រូវ តំបន់ឃ្លាំងកប់ស្រូវនេះ តើជាវាលស្រែ ហើយមានអគារដែរទេ? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាលោកនៅធ្វើការនៅទីនោះមួយរយៈ ដើម្បីឲ្យយើងខ្ញុំបានយល់ថា តើលោក សូមលោករៀបរាប់អំពីទីតាំងភូមិសាស្ត្រឃ្លាំង និងកប់ស្រូវជូនអង្គជំនុំជម្រះបន្តិចបានទេ?

**ឆ៖** ខ្ញុំបាទសូមរៀបរាប់ជូនអង្គតុលាការសូមមេត្តាទានជ្រាប។ នៅឃ្លាំងនិងកប់ស្រូវ គឺនៅតាមផ្ទះរបស់ប្រជាជនដែលគេជម្លៀសចេញទៅ នៅភូមិចាស់របស់គេ គឺមានផ្ទះដែលនៅសេសសល់ក៏នាំគ្នានៅកន្លែងហ្នឹងទៅ ដល់គេឲ្យនៅ។

**ស៖** តើត្រឹមត្រូវដែរទេដែរថា លោកបានចូលរួមប្រជុំជាច្រើនដង នៅពេលដែលនៅក្នុងកិច្ចប្រជុំនោះ គឺត្រូវបានគេយកមនុស្សចេញទៅបាត់ គេចាប់ខ្លួនយកចេញទៅបាត់។ តើត្រឹមត្រូវដែរទេ?

[១៥:៥១:១០]

**ឆ៖** រឿងដែលគេហៅប្រជុំច្រើនដង ហើយគេចាប់មនុស្សចេញទៅបាត់ៗ ខ្ញុំសូមឆ្លើយជូនអង្គតុលាការគឺពិតប្រាកដមែន។ នេះខ្ញុំបានសុំស្បថជូនអង្គតុលាការ គឺបានឃើញដោយពិតប្រាកដ។

**ស៖** តើមូលហេតុអីបានជាលោកទៅប្រជុំ? ពីព្រោះថា ភ្លាមៗនោះលោកដឹងថា បើសិនណាជាលោកទៅចូលរួមប្រជុំ លោកអាចត្រូវគេចោទប្រកាន់ លោកអាចត្រូវបានគេចាប់ខ្លួនយកទៅបាត់។ ហេតុអ្វីក៏លោកទៅចូលរួមប្រជុំធ្វើអី បើលោកដឹងថាវាអាចមានរឿងអីចឹងកើតមកដល់រូបលោក?

**ឆ៖** ខ្ញុំបាទស្ដាប់មិនទាន់បាន សូមមេត្តាបញ្ជាក់ម្ដងទៀតទានប្រុស។

**ស៖** បាទ ខ្ញុំកែសម្រួលសំណួរបន្តិច។ តើលោកមានជម្រើសណាផ្សេងបានទេ គឺថា តើលោកអាចមានជម្រើសទៅប្រជុំក៏បាន មិនទៅប្រជុំក៏បាន បានដែរឬទេ?

**ឆ៖** នៅពេលនោះមិនអាចមានជម្រើស។ តែគេហៅទៅប្រជុំស្ដាប់គេ គឺត្រូវតែទៅបាទ។ អត់អាចអាក់ខានបាន តែយើងតវ៉ា គេថាយើងខ្មាំង។ តែគេឲ្យធ្វើម៉េចគឺធ្វើតាមតែគេទាំងអស់បាទ។

**ស៖** អ្នកណាជាអ្នកកោះហៅទៅប្រជុំនៅក្នុងពេលថ្ងៃ ឧទាហរណ៍ថាលោកកំពុងធ្វើការ។ គឺថាអ្នកណាត្រូវមកហៅទៅប្រជុំ? ចុះសមាជិកនៅក-៤ ដឹងដោយរបៀបណាដែរ? អ្នកណាជាអ្នកប្រាប់លោក? គេប្រាប់ពេលថ្មើរណា? គេប្រាប់ដោយរបៀបណា?

[១៥:៥៣:៤៩]

**ឆ៖** ខ្ញុំបាទសុំឆ្លើយអង្គតុលាការ សូមមេត្តាទានជ្រាប។ នៅពេលដែលគេចាប់ប្រធានកងវរៈ អនុប្រធាន និងសមាជិកកងវរៈក-៤នេះទៅ គឺមានពួកភូមិភាគនិរតីគេមកក្តាប់។ គេមកក្តាប់នៅអង្គភាព ក-៤ ដូច្នេះពេលហៅប្រជុំគឺពួកនោះ គេមានខ្សែបណ្តាញគេហៅប្រជុំបាទ។ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** តើលោកបានឃើញមនុស្សដដែលឬ ដែលមកចាប់ខ្លួនសមាជិកនៅក្នុងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត? តើអ្នកដែលមកចាប់រាល់ពេលប្រជុំ ឬក៏រាល់ពេលចាប់ខ្លួនហ្នឹងគឺថាជាមនុស្សដដែល ឬក៏លោកឃើញមុខផ្សេងដែរ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការត្រង់ចំណុចនេះ។ អ្នកដែលមកចាប់ខ្លួនមានមុខមិនដដែលទេ គឺខុសគ្នាបាទ។

**ស៖** លោកបានឆ្លើយថាលោកបានដឹងអំពីគុកទួលស្លែងនិងព្រៃស ដោយសារៗអ្នកចាប់ខ្លួនហ្នឹងប្រាប់លោក។ តើត្រឹមត្រូវដែរទេ ដែលថាលោកដឹងថាមានមន្ទីរសន្តិសុខ នៅពេលដែលលោកនៅឃ្មួញនៅកប់ស្រូវហ្នឹង គឺថាលោកដឹងមានមន្ទីរសន្តិសុខពីរហ្នឹង?

**ឆ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការសូមមេត្តាជ្រាប។ នៅឃ្មួញនិងកប់ស្រូវ គឺថ្នាក់ភូមិភាគឧត្តរ គ្មានអ្នកណាដឹកនាំទេគឺនៅជាយុទ្ធជនទាំងអស់។ នៅពេលនោះ ភូមិភាគនិរតី ពេលណាប្រជុំម្តងៗគេថា "អាណាខ្ជិលធ្វើការ អាណាខ្ជិលច្រអូស គេឲ្យទៅគុកព្រៃស និងគុកទួលស្លែង" នេះខ្ញុំបាទនៅចាំបាននៅពេលនោះ។ បាទ សូមមេត្តាជ្រាប។

[១៥:៥៦:៥៥]

**ស៖** សូមអរគុណ។ តើបរិយាកាសនៅពេលនោះ វាដូចម្តេចដែរ បរិយាកាសនៅឯឃ្មួញ និងកប់ស្រូវ។ នៅពេលមានការចាប់ខ្លួនរាល់ៗយប់ គេចាប់ខ្លួនមនុស្សយកទៅបាត់ពីកងរបស់លោក ពីកងផ្សេង? តើលោកមានអារម្មណ៍ដូចម្តេចដែរ ពេលដែលលោកស្ថិតនៅក្នុងស្ថានភាពបែបនេះ? អ៊ីចឹងសូមលោកពន្យល់ជូនតុលាការបន្តិចបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាប។ នៅពេលនោះ អារម្មណ៍គឺមិនស្ថិតស្ថេរ តែងតែមានការព្រួយបារម្ភអំពីសេចក្តីស្លាប់របស់ខ្លួន ដោយសារឃើញគេចាប់រាល់ថ្ងៃ។ ដូច្នេះអារម្មណ៍របស់ខ្ញុំបាទ វាមានការភ័យព្រួយ តក់ស្លុតដ៏ក្រៃលែងនាពេលនោះ។

**ស៖** សូមអរគុណលោក។ លោកសាក្សី ខ្ញុំសូមបង្ហាញឯកសារមួយ -- បញ្ជីឈ្មោះមនុស្ស។ ឯកសារគឺ E3/342។ ជាឯកសារបញ្ជីអ្នកទោសមកពីស-២១ ដែលមានបញ្ជីមនុស្សរហូតដល់ជាង ១២.០០០នាក់បញ្ជូនទៅគុកទួលស្លែង គឺមានឈ្មោះមួយនៅលើបញ្ជីនេះ។

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាត ដើម្បីបង្ហាញឯកសារនៅលើអេក្រង់ ជូនសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៥៩:១៧]

**លោក វីណ្ឌៀម ស្មីត៖**

បាទ ឯកសារនេះ គឺនិយាយអំពីចំនួនអ្នកទោសមានចំនួន៨.៩៦០ -- នៅត្រង់លេខរៀងទី ៨៩៦៧។ បាទ សូមមេត្តាជួយពង្រីកឲ្យធំបន្តិច។ ដែលកំពុងរង់ចាំមើលការពង្រីកឯកសារនេះ ការបង្ហាញឯកសារនេះ ប្រហែលជាខ្ញុំសូមបង្ហាញនៅថ្ងៃចន្ទវិញ គឺសូមបង្ហាញឯកសារមួយផ្សេងទៅវិញ។ បើសិនជាលោកប្រធានយល់ឃើញថាដល់ម៉ោងឈប់ ក៏ខ្ញុំនឹងបន្តដល់ថ្ងៃស្អែកដោយសារសំណួរនេះវាធំធេងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណល្មមពេលសម្រាកហើយ ព្រោះថ្ងៃនេះថ្ងៃសុក្រផង។

សវនាការថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៥ ខែមិថុនា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កែវ លឿ និងអាចផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-901 ហើយនិងសូមបញ្ជាក់ថា បន្ទាប់ពីសាក្សី 2-TCW-901 គឺសាក្សី 2-TCW-830 សម្រាប់អង្គហេតុការដ្ឋានទំនប់១មករា។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

[១៦:០១:១៥]

អង្គជំនុំជម្រះសូមអរគុណដល់លោក កែវ លឿ ដែលបានដំណើរការសវនាការសម្រាប់ថ្ងៃនេះមិនទាន់ចប់ទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ទី១៥ ខែមិថុនា ឆ្នាំ២០១៥

ទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ឥឡូវនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី កែវ លឿ វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមអញ្ជើញគាត់ ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី១៥ ខែមិថុនា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*